# ការសាកល្បងពិចារណា

## បញ្ញវន្តខ្មែរ



និពន្ធ ដោយ ឧប សៅ សង្ហា

# មាតិការឿង

បុព្វកថា 1
លក្ខខ័ណ្ឌ ចាត់ ទុក ជា បញ្ញាវន្ត 4
មរតក របស់ បញ្ញាខ្មែរ 17
វប្បដ្ឋាន 33
ប្រភេទ នៃ បញ្ញាវន្តខ្មែរ 41
សេចក្ដីសន្និដ្ឋាន 72




# បុព្វកថា

តើ ខ្មែរ គ្រប់សម័យ ដែល ជា មនុស្សលោក មាន ការផ្លាស់ប្តូរ ដែរ ឬ ?

ការវិវត្តរ៍ នៃ អារ្យធម៌ និង វប្បធម៌ ជា មាគ៌ា នៃ វិវឌ្ឍនៈ របស់ មនុស្សលោក និង សង្គម មនុស្ស។ ដូច្នេះ ខ្មែរ ដែល ជា មនុស្សលោក ក៏ មាន ការវិវត្តរ៍ ក្នុង ចរន្ត មនុស្សជាតិ ដូច ជាតិសាសន៍ ដ៏ទៃទៀត ដែល ជា មនុស្សលោក នោះដែរ។

ខ្មែរ តែង និយាយ ថា ខ្លួន ជា ពង្សាវលី ខ្មែរអង្គរ ដែល ជា ជាតិសាសន៍ ធ្លាប់ មាន អារ្យធម៌ និង វប្បធម៌ ខ្ពង់ខ្ពស់ ជា វេទិជន ចេះ គ្រប់ វិជ្ជា សំរាប់ ធ្វើ មនុស្សបូនីយកម្ម និង សង្គមបូនីយកម្ម ដើម្បី បង្កើត បូរិម្យ សំរាប់ ជាតិសាសន៍ខ្លួន។ តែ បើ យើង ធ្វើ ការសង្កេត លើ ភាវរូប សង្គម ខ្មែរ បច្ចុប្បន្ន យើង ឃើញ ថា ពណ៌នា ខាង លើ នេះ ហាក់ បី ដូច ជា គ្មាន ធាតុ ពិត ណាមួយ អាច បញ្ជាក់ ច្បាស់ ថា ខ្មែរ អង្គរ និង ខ្មែរ បច្ចុប្បន្ន មាន ពង្សាវលី តែ មួយ

និពន្ធ ដោយ ឧប សៅ សង្ហា
២០១៥ (អត្ថបទ ពិនិត្យ និង សរសេរ ឡើងវិញ នៅ ឆ្នាំ ២០១៧)

ព្រោះ គំនិត នៃ ការកសាង ប្រជាជាតិ វា មាន ភាព ផ្ទុយ គ្នា ស្រឡះ។ ភាពនេះ បង្ហាញ ថា ការវិវត្ត នៃ អារ្យធម៌ និង វប្បធម៌ ខ្មែរ ហាក់ បី ដូច បាន ជួប ឧបសគ្គ អ្វី មួយ កាត់ ចរន្ត វិវត្តរ៍ ឲ ដាច់ ពី ភាពថ្កុំថ្កើង នៃ ខ្មែរ អង្គរ។ យើង សួរ ថា មូលហេតុ អ្វី ដែល នាំ ឲ មាន ការកាត់ផ្តាច់ នេះ ?

នៅទីនេះ យើង មិនលើកយក មូលហេតុ កើត មកពីសង្គ្រាម ឬ ការរាតត្បាតបរទេស មក ធ្វើ អត្ថាធិប្បាយ នោះ ទេ ព្រោះ មាន អ្នកប្រាជ្ញបរទេស និង ជាតិ នៃ នរវិទ្យា ច្រើនណាស់ គេ បាន យក មក ធ្វើ ការសិក្សា ច្បាស់លាស់ តាម វិធី វិទ្យាសាស្ត្រ បង្ហាញ អំពី ការយល់ឃើញ របស់ គេ នៃ ហេតុផល ទាំងនោះ រួច មក ហើយ។ ការសិក្សា ទាំងឡាយ នោះ បាន ក្លាយ ជា គំនិត អនញ្ញ (pensée unique) ហើយ ជា ចំណេះសាកល មិន អាច អោយខ្មែរ ដ៏ទៃទៀត អាច មាន លទ្ធភាព បញ្ចេញ ជា យោបល់ ផ្សេង ផ្ទុយ អំពី ការចេះដឹង នេះ នោះឡើយ តែ ខ្មែរ យើង ក៏ មិន សូវ បាន យក ហេតុផល ទាំងនោះ មក ធ្វើ ការពិចារណា រក ការពិត ឬ អ្វី ដែល ជា គំនិតខ្មែរ ដូច្នេះ ហើយ បាន យើង មិន សូវ មាន ប្រតិកម្ម ជា វិជ្ជមាន

ក្ដី ជា អវិជ្ជាមាន ក្ដី អំពី មូលធន បញ្ញាខ្មែរ ដែល អ្នកប្រាជ្ញបរទេស គេ យក មក ធ្វើ ជា បញ្ញា ផ្ដាច់មុខ របស់គេ ជា ពិសេស នៅ ក្នុង ផ្នែក វប្បធម៌ និង អារ្យធម៌ខ្មែរ។ ចំណុច នេះហើយ ដែល នាំ ឲ យើង ចង់ ពិចារណា អំពីបញ្ញាខ្មែរ ដែល ជា គ្រឿងយន្ដ នៃ ការចំរើន លូតលាស់ នៃសង្គមខ្មែរ។




# លក្ខខ័ណ្ឌ ចាត់ ទុក ជា បញ្ញវន្ត

## លក្ខខ័ណ្ឌណាខ្លះដែលខ្មែរយើងចាត់ទុកជាបញ្ញវន្ត ?

នៅក្នុង គំនិតខ្មែរ សម័យ បញ្ញវន្ត គឺ ជា ជន ដែល បាន រៀនសូត្រ ហើយ បាន ទទួល សញ្ញាប័ត្រ ថ្នាក់ឧត្តមសិក្សា។ ក្នុង ទស្សនៈនេះ ខ្មែរយើង វៃត ម្លៃ ទៅ លើ ការចេះដឹង កើត មាន ឡើង ពី ការសិក្សា ក្នុង មុខវិជ្ជា ណាមួយ ហើយ ត្រូវ រដ្ឋ ឬ អង្គការ ណាមួយ គេ ទទួលស្គាល់ នូវ ការចេះដឹង តាម ខ្នាតមួយ ដែល គេ បង្កើត ឡើង សំរាប់ វាយ តម្លៃ នៃ ការចេះដឹង របស់ អ្នកសិក្សា ហើយ បើ អ្នកសិក្សា នោះ បាន រៀនសូត្រ ចេះដឹង ក្នុងកំរិត ដែល គេ បាន ធ្វើ ការកំណត់ ថា អាច ចាត់ ទុក ជា អ្នកចេះដឹង គេ សម្រេច ប្រគល់ សញ្ញាប័ត្រ ដល់ ជន នោះ ដើម្បី បញ្ជាក់ អំពី ការទទួលស្គាល់ របស់ គេ។ ទស្សនៈ នេះ ជា ទស្សនៈ ចង្អៀត មួយ នាំ បន្ថយ អត្ថន័យ នៃ ពាក្យ បញ្ញាវន្ត និង អោយ មាន ការភាន់ច្រឡំ ក្នុង ការប្រើ ពាក្យ បញ្ញវន្ត។

និពន្ធ ដោយ ឧប សៅ សង្ហា
២០១៥ (អត្ថបទ ពិនិត្យ នឹង សរសេរ ឡើងវិញ នៅ ឆ្នាំ ២០១៧)

គួរ យើង ត្រូវ ដឹង ដែរ អំពី ការចាត់ ថ្នាក់ បញ្ញាវន្ត នៅ បស្ចឹមប្រទេស ដែល មាន ចែក បញ្ញាវន្ត ជា ៤ ថ្នាក់៖

ទី១. គឺ ជា អ្នកនិពន្ធ សិល្បករ (ការី) និង អ្នកប្រាជ្ញ ;

ទី២. គឺ ជា សាស្ត្រាចារ្យ មហាវិទ្យាល័យ អ្នកស្រាវជ្រាវ និង អ្នកសរសេរនិទ្ទា (សរសេររិះគន់) ;

ទី៣. គឺ ជា អ្នកសារព័ត៌មាន និង អ្នកសរសេរផ្សាយ គំនិត និង ចំណេះ អ្វីមួយ ;

ទី៤. គឺ ជា វិជ្ជបណ្ឌិត វិស្វករ យុត្តិវិទូ (អ្នកច្បាប់) និង បណ្ឌិត ផ្នែក មុខវិជ្ជា អ្វីមួយ។

នៅក្នុង ទស្សនៈ នេះ គេ បែងខ្ចែង ជា គំនិត **មូលដ្ឋាន**[1] ធំ ពីរ៖

១. គំនិត ឈរ លើ ការចេះដឹង ចំណេះអ្វីមួយ ដែល អាច បង្ហាញ បាន ភ្លាម នូវ ភាពស័ក្តិសិទ្ធិ នៃ ចំណេះ នោះ និង គំនិត ឈរ លើ វប្បធម៌ នៃ ការចេះដឹង។

---

[1] មូលដ្ឋាន= Polarité។

២. គំនិត ឈរ លើ ការយកមក ធ្វើតាម នូវ ចំណេះ ណា មួយ និង គំនិត ឈរ លើ ការបង្កើត ជា ដំបូង នូវ គំនិត ឬ វត្ថុ អ្វី មួយ។

បើ យើង យក ទស្សនៈ បស្ចឹមប្រទេស មក ប្រៀបនឹង គំនិតខ្មែរ យើង ឃើញ ថា គំនិត នេះ មាន មួយ ផ្នែក ក្នុង គំនិតខ្មែរ ដែរ ដូច ជា គំនិត ឈរ លើ «ភាព ស័ក្តិសិទ្ធិ» (ក្នុង គំនិត ទី១) និង គំនិត ឈរ លើ «ការយក មកធ្វើតាម» (ក្នុង គំនិត ទី២)។ ក្នុង គំនិត ទី១ ខ្មែរ តែង ឲ តម្លៃ ទៅ លើ អ្នកចេះដឹង នៅ ពេល ណា ឃើញ ថា ចំណេះ អ្នកចេះដឹង នោះ មាន ភាពស័ក្តិសិទ្ធិ គឺ អាច ទាញ យក ជា ប្រយោជន៍ បាន ភ្លាមៗ សំរាប់ ការរស់នៅ ក្នុងជីវិត ដូច ខ្មែរ តែងតែ យល់ឃើញ ថា បើ ចេះ ទាល់តែ មាន បុណ្យស័ក្តិ និង លុយកាក់ ទើប ជា អ្នកចេះ ហើយ មួយទៀត បើចេះ ទាល់ តែ ចេះសូត្រ រត់មាត់ តាម គ្រូ ដូច ខ្មែរ យើង តែង និយាយ ថា រៀនសូត្រ នោះឯង។

នៅក្នុង គំនិត នេះបង្ហាញ ថាខ្មែរយើង មិន សូវឲ តម្លៃ លើ គោលការ វប្បធម៌ និង លើ គោលការ បង្កើត នូវ គំនិត ឬ ការរកឃើង អ្វីមួយថ្មី សំរាប់ សង្គម ព្រោះ ថា វប្បធម៌ ជា វត្ថុ អរូបី ឯ ចំណែក អ្វី ថ្មី ជា ការជំទាស់នឹង បរេណី និង ទំនៀមទម្លាប់។ ទស្សនៈ នេះ ជា ច្បាប់ រស់នៅ របស់ ប្រជាពលរដ្ឋ ក្នុង សង្គម អភិរក្ស មាន ចែក ជា វណ្ណៈ ពី កំណើត គឺ ពួក មាន ត្រកូល ជា អ្នកធំ ជា ម្ចាស់ និង ពួក មាន វណ្ណៈជា អ្នកតូច ជាឈ្នួល។ វណ្ណៈទាំងពីរ នេះ មាន ព្រំដែន ជិតស្លុង មិន អាច ឆ្លងកាត់ បាន ពី វណ្ណៈ មួយ ទៅ វណ្ណៈ មួយ។ ហេតុ នេះឯង បាន ជា ខ្មែរ យល់ឃើញ ថា អ្នកចេះ កើត ក្នុង ត្រកូល តូច គឺ នៅ តែ តូច ដដែល លុះ ត្រា តែ ជន នោះ មាន ភ័ព្វសំណាង ពិសេស ក្លាយ ទៅ ជា អ្នកមានយសស័ក្តិ ទើប គេ ទទួល ស្គាល់ ចំណេះ ដែល ខ្លួន មាន នោះ។

នៅក្នុង ទស្សនៈ ដែល បានរៀបរាប់ ខាងលើ នេះ យើង ង្កេតឃើញ ពិត ថា នៅក្នុង សង្គម គេ ពុំ ឲ តម្លៃ ទៅ លើ អ្នកនិពន្ធ សិល្បករ(ការី) អ្នកនិន្ទា អ្នកសារព័តិមាន ព្រោះ

ជា ពួក មនុស្ស រស់នៅ ក្នុង លោកអរូបី បង្កើត តែ គំនិត ឥតបានការ សំរាប់ តែ បំរើ មនោសញ្ចេតនា អ្នកដទៃ គឺ ចេះ ឥតប្រយោជន៍ សំរាប់ ការរស់នៅ របស់ ខ្លួន។ ពួក ទាំងនោះ ច្រើន តែ ជា មនុស្ស ក្រលំបាក គ្មាន យស ស័ក្តិ កើត ក្នុង ត្រកូល តូច គេ ទុក ជា ជន កំប៉ិ កកំប៉ុក ដែល ខ្មែរយើង ច្រើន ហៅ ពួក មនុស្ស បែបនេះ ថា «អានេះ អានោះ» ដូច គេ នាំ គ្នា ហៅ លោក ស៊ីន ស៊ី សាមុត ជា អ្នកចំរៀង ដ៏ឆ្នើម «អា ស៊ីន ស៊ីសាមុត» នោះ ឯង។ យើង ដឹង ថា នៅក្នុង សង្គមសក្តិភូមិខ្មែរ អ្នក កើតក្នុង ត្រកូលធំ តែងតែ ហៅ ជន ដែល កើត ក្នុង ត្រកូលតូច ទោះ បី អ្នកនោះ មាន អាយុ ច្រើន ជាង ក៏ ដោយ ថា «អានេះ អានោះ» ជានិច្ច។

ដោយ យោង លើ គំនិត ភាពស័ក្តិសិទ្ធិ នៃ ចំណេះ សំរាប់ ការរស់នៅ យើង សង្កេត ឃើញ ថា យុវជនខ្មែរ ចូលចិត្ត រៀន វិស័យ វិទ្យាសាស្ត្រ និង បច្ចេកទេស។ ចំនួន យុវជន មាន តិចតួច ណាស់ ដែល បាន ជ្រើសរើស នរវិទ្យា, ទស្សន វិជ្ជា ព្រោះ វិជ្ជា ទាំង នេះ គេ ទុក វា ថា គ្មាន ភាព

ស័ក្តិសិទ្ធិ សំរាប់ ការរស់នៅ ហើយ ពិបាកនឹង រក ការងារ ធ្វើ ផង។

## ងារ របស់ បញ្ញាវន្ត

បញ្ញាវន្ត មិនមែន ជា ងារ ដែល ជន ម្នាក់ៗ អាច តាំង ខ្លួនឯង បាន នោះឡើយ។ ជន បែប នេះ ក្នុង ពាក្យខ្មែរ គេ ហៅ «បណ្ឌិត មានះ»។ ការប្រកាស់ ថា ខ្លួន ជា បញ្ញាវន្ត គឺ ជា មានះ របស់ អ្នកល្ងង់ ដែល លើក ខ្លួន ដោយ ខ្លួនឯង ថា ខ្លួន ជា ឧត្តមជន។

ងារ ជា បញ្ញាវន្ត ជា ងារ ដែល មិតិសាធារណៈ តាំង ឲ ជន ណាមួយ ដែល មាន សកម្មភាព យ៉ាងខ្ចីឃ្លាត ក្នុង ផ្នែក គំនិត ប្រកប ដោយ គុណធម៌ សំរាប់ ប្រយោជន៏ សង្គម និង ប្រយោជន៏ មនុស្សជាតិ។ ចរិតលក្ខណៈ នៃ បញ្ញាវន្ត គឺ ថិត នៅ លើ អ្វី ដែល ជា គតិបណ្ឌិត ការពារ សេចក្ដី ថ្លៃថ្នូរ របស់ មនុស្សជាតិ។

## គេ មាន វិធី ពីរ សំរាប់ ទទួល ស្គាល់ ងារ ជា បញ្ញាវន្ត

ទី១ គឺ វិធី តាម ការចូលរួម ក្នុងសកម្មភាព ដែល គេ ទុក ថា មាន លក្ខណៈ ជា សកម្មភាព មាន តម្លៃ ក្នុង ផ្នែក បញ្ញា (mode d’affiliation)។

ទី២ គឺ វិធី ដែល មាន ក្នុង តម្លៃផ្ទាល់ ទៅ លើ បុគ្គល ម្នាក់ ដែល ទុក ស្រេច ថា គាត់ ជា បញ្ញាវន្ត ព្រោះ មនុស្ស នោះ មាន ចរិត ជា សុជន មាន ចំណេះ ជា បណ្ឌិត ដែល គេ មើលឃើញ ជាក់ស្តែង ឥត អាច ប្រកែក បាន (mode de légitimation)។

ខ្មែរ បុរាណ មាន ពាក្យ មួយ ស្រប ទៅ លើ គុណភាព នៃ បញ្ញាវន្ត គឺ «បណ្ឌិត»។ បណ្ឌិត គឺ ជា អ្នកចេះដឹង ហើយ បាន ធ្វើ អ្វី មួយ ក្នុង គុណធម៌។ ដូច្នេះ ខ្លឹមសារ នៃ ងារ បញ្ញាវន្ត គឺ ផ្អែក លើ គោលការណ៍ ពីរ៖ «សកម្មភាព និង គំនិត ក្នុង គុណធម៌»។ តែ គេ មិន ទុក បញ្ញាវន្ត ជា «គន្ធរចនាចារ្យ» (moraliste) នោះ ដែរ ព្រោះ បញ្ញាវន្ត មិន មែន ជា អ្នក ធ្វើការទូន្មាន ប្រៀនប្រដៅ ដល់ ជន ដ៏ទៃ ដូច ពួក បុព្វជិត ឬ ភិក្ខុសង្ឃ នោះឡើយ។ អ្វី ជា បណ្ឌិត គឺ បាន ធ្វើអ្វីមួយ ដោយ ឥត យក គំនិត រក

ប្រយោជន៍ ជា គំនិត សំខាន់ ហើយ តម្រូវ ឲ អ្នក ដទៃ ធ្វើ តាម ខ្លួន។

**សួរ ថា តើ នៅក្នុង សង្គមខ្មែរ គ្រប់ សម័យ មាន បញ្ញាវន្ត ដែរ ឬ ទេ ?**

នៅក្នុង សម័យ បុរាណ សង្គមខ្មែរ ច្បាស់ ជា មាន បញ្ញាវន្ត ដែល មាន ងារ ជា បណ្ឌិត។ បណ្ឌិត ជា ជន មាន ប្រាជ្ញា ជន អ្នកប្រព្រឹត្តល្អ គឺ អ្នកកាន់ សុចរិត ដោយ ពិស្តា ដោយ ខ្ជាប់ខ្ជួន ហ្មត់ចត់ ជា និច្ច គឺ ជា អ្នកប្រាជ្ញ ខាង ផ្លូវ សុចរិត យុត្តិធម៌។ នៅក្នុង សម័យ ពុទ្ធសាសនា បណ្ឌិត ជា អ្នកបួស ព្រោះ អ្នកបួស មាន ការចេះដឹង មាន ចរិយា មារយាទ ត្រឹមត្រូវ។ រួច ក្រោយមក ពាក្យ បណ្ឌិត នេះ ហៅ ក្លាយ ជា «បន្ទិត» ហើយ ឃ្លាយ មក ទៀត ជា «អន្ទិត»។ សម័យ ទំនើប គេ ហៅ អ្នក មានវិជ្ជាថ្នាក់ ខ្ពស់ ដែល មាន សញ្ញាបត្រ «ដុកតូរ៉ាត» ថា បណ្ឌិត ក្នុង មុខ វិជ្ជា អ្វីៗ មួយ។ (ដកស្រង់ ពី វចនានុក្រមខ្មែរ សម្តេច ជួនណាត ជោតញ្ញាណោ បោះ ពុម្ព គ្រា ទី៥ ក្នុង ឆ្នាំ ១៩៦៧ ត្រូវ នឹង ព.ស. ២៥១១)។

ការក្លាយឃ្លាត ពាក្យ បណ្ឌិត មក អន្ទិត ជា ការក្លាយ ថយ ចុះ នូវ គុណសម្បត្តិ នៃ បណ្ឌិត។ ការក្លាយនេះ ជា សញ្ញា នៃ ភាពអត្ថង្គត នៃ សង្គមខ្មែរ។ បណ្ឌិត ដែល មាន ភារៈ ជា ឧត្តមជន ដែល មាន ឯករាជ្យ នៃ ការវិវត្តន៍ គំនិត ខ្ពង់ខ្ពស់ សំរាប់ ជា យាន នៃ ការចំរើន នៃ សង្គម បាន ក្លាយឃ្លាត ត្រឹមតែ ជា សុជន (មនុស្សល្អ) ចេះ ធម៌ សំរាប់ តែ ធ្វើ ជា អាចារ្យវត្ត ឬ ពិធិការ តែប៉ុណ្ណោះ។ ការក្លាយ នេះ ជា ការក្លាយឃ្លាត ពី «ថាមវិន្តភាព» ទៅ «និច្ច លភាព » ឬ ពី អ្វី ដែលមាន រូបភាព ជា «សកម្មភាព» ទៅ រក អ្វី ដែល មាន រូបភាព «អភិរក្សនិយម»។

យើង និយាយ នេះ គ្មាន បំណង ចង់រិះគន់ ព្រះពុទ្ធ សាសនា នោះឡើយ យើង មាន ជំនឿ ជា និច្ច ថា ព្រះពុទ្ធ សាសនា មាន ប្រយោជន៏ ណាស់ សំរាប់ សង្គមជាតិ ព្រោះ ជា សាសនា នាំ រំដោប់ នូវ អ្វី ដែល ជា ធាតុ នៃ ទុក្ខ របស់ មនុស្សលោក តែ ធម៌សាសនា ម្នាក់ឯង ពុំ អាច ឲ មនុស្ស លោក រកឃើញ នូវ អ្វិ ដែល ជា ខ្លឹមសារ នៃ សុភ មង្គល ក្នុង ធាតុ ខ្លួន ជា សត្វលោក ដែល ជា ធាតុ ចាំបាច់សំរាប់ ជីវិត ជា សត្វលោក គឺ មាន ឃ្លាន និង ចង់

សុខ ក្សេមក្សាន្ត។ ធម៌ សាសនា ជា យោង នៃ មនុស្ស ធម៌ ឯ ចំណែក វប្បធម៌ ជា យាន នៃ ការចំរើន របស់ មនុស្សលោក។ យាន ទាំង ពីរ ត្រូវ ការយោងគ្នា ទៅវិញ ទៅមក ដើម្បី ធ្វើ អភិវឌ្ឍន៍ នៃ សង្គមមនុស្ស ក្នុង គន្លង ធម៌។

## នរណា ទៅ ជា បណ្ឌិត នៅ ស្រុកខ្មែរ ?

នៅក្នុង សម័យ ព្រាហ្មណ៍សាសនា បណ្ឌិត មាន នៅក្នុង ពួក ព្រាហ្មណ៍ ដែល ជា វណ្ណៈទី១ ក្នុង ចំណោម វណ្ណៈទាំង បួន នៃ លទ្ធិព្រាហ្មណ៍។ វណ្ណៈ ទាំងនោះ មាន៖ ទី១. ព្រាហ្មណ៍ ទី២. ក្សត្រិយៈ ទី៣. វេស្សៈ ទី៤. សូទ្រៈ។

ព្រាហ្មណ៍ ជា បណ្ឌិត ជា គ្រូអាចារ្យ ថ្នាក់ឧត្តម នៃ មហាវិទ្យាល័យ បង្ហាត់ បង្រៀន វិជ្ជា ផ្សេងៗ ដល់ យុវជន ដែល មាន វណ្ណៈ ជា ព្រាហ្មណៈ និង ក្សត្រិយៈ ; ជា ពិសេស ជា វរៈគ្រូ របស់ ព្រះមហាក្សត្រ បង្ហាត់ បង្រៀន វិជ្ជា មនុស្សសាស្ត្រ, នយោបាយ, យុទ្ធសាស្ត្រ និង គ្រប់ មុខវិជ្ជា ឯទៀត សំរាប់ ធ្វើការដឹកនាំ ប្រទេសជាតិ។ ពួកព្រាហ្មណ៍ ក៏ ជា អ្នក សិក្សា ស្រាវជ្រាវ និង បង្កើត វប្បធម៌ និង គ្រប់ច្បាប់រដ្ឋ សំ

រាប់ រាជការ និង ប្រជារាស្ត្រ។ ព្រាហ្មណ៍ បណ្ឌិត ចូលរួមយ៉ាងសកម្ម ក្នុងកិច្ចការលោកកិយ, កិច្ចការប្រាជ្ញា ក៏ដូចជា កិច្ចការ សាសនា ក្នុង ព្រះរាជអាណាចក្រ ជា នាដការមាន ចេស្តា ក្នុង សង្គមខ្មែរ។

មក ដល់ ពោធិសម័យ ចេស្តា ព្រាហ្មបណ្ឌិត មាន ការអន់ថយក្រៃលែង។ ក្នុង តួនាទី បណ្ឌិត ត្រូវ គេ ផ្លាស់យក ពួកភិក្ខុសង្ឃ មក ដើរតួ ជំនួស។ ការផ្លាស់ បន្ទុក នេះ កើតមក ពី ការផ្លាស់ ជំនឿសាសនា របស់ ព្រះមហាក្សត្រ។ ជាការផ្លាស់ប្តូរ នាំ ឲ មាន ការកែប្រែ ជាខ្លឹមសារ នៃ អត្ថន័យ នៃ តួនាទី របស់ បណ្ឌិត។ គោលដៅ របស់ រាជអំណាច ក្នុង ពោធិសម័យ គឺ ចង់ធ្វើ ប្រជាធិតេយ្យបនីយកម្ម ក្នុង វិស័យ សិក្សា ធិការជាតិ ដោយ បន្ថយ ឯកាធិភាព ពួកព្រាហ្មណ៍ ក្នុង វិស័យ នេះ។ អំពើនេះ គឺ ជា ការធ្វើ បដិវត្តន៍ វប្បធម៌ មួយ ក្នុង ជំនាន់នោះ។

ព្រះមហាក្សត្រ ដែល បានធ្វើ អំពើនេះ មាន ប្រជាប្រិយភាព ក្រៃលែង ដូចយ៉ាង ព្រះបាទជ័យវរ្ម័នទី៧។ ភិក្ខុសង្ឃណា ដែល មាន ចំណេះជ្រៅជ្រះ ក្នុង ធម៌ព្រះពុទ្ធ ត្រូវគេទទួលស្គាល់ ថា ជា បណ្ឌិត ស្មើមុខនឹង ព្រាហ្មណ៍បណ្ឌិត នាំ

ឲ ពួកទាំងនោះ មាន ការអាក់អន់ចិត្ត ក្រាសក្រែង ហើយ ពួក ព្រាហ្មណ៍បណ្ឌិត ដែល ជា គ្រូអាចារ្យធំៗ និង ជាបាគួរ នាំគ្នា រត់ចេញ ពី ស្រុកខ្មែរ ដោយ នាំយក ទៅជាមួយ ពួកគាត់ នូវ គម្ពីធម៌ និង យុទ្ធសាស្ត្រនយោបាយ សំខាន់ៗ ជា ច្រើន(សូមអានរឿង តាត្រសក់ផ្អែម ក្នុងឯកសារ « មហាបុរសខ្មែរ» ស្រាវជ្រាវដោយលោក អេង សុត)។

ដល់មក សម័យទំនើប ខ្មែរយើង ទុក អ្នក មាន សញ្ញាប័ត្រ មហាវិទ្យាល័យ ជា បញ្ញវ័ន្ត។ ការសំគាល់ តាម លក្ខណៈ នេះ នាំ ឲ មាន ការផ្លាស់ អន្ថន័យ បញ្ញវន្ត ពី ន័យ «អ្នក ធ្វើ ជីវិត នៃ គំនិតប្រាជ្ញា អោយ មាន ដង្ហើម ជា អចិន្ត្រៃ» ក្នុង សង្គម មកត្រឹមតែ ជា «អ្នកចេះដឹង នៃ មុខ វិជ្ជា វិទ្យាសាស្ត្រ អ្វីមួយ តែប៉ុណ្ណោះ»។ ក្រៅពីនេះទៅ ទៀត ន័យ បញ្ញវន្ត បាន ក្លាយ ទៅ ជា ឋានៈ ឬ វណ្ណៈថ្មី មួយ នៅក្នុង សង្គមខ្មែរ។ អ្នកបញ្ញវន្ត បំពាក់ ដោយ សញ្ញាប័ត្រ តាំង ខ្លួន ជា លោកធំ រស់លើភាពល្ងង់ខ្លៅ របស់ អ្នកតូច ដែល ជា រាស្ត្រសាមញ្ញ ដោយ ទុក ខ្លួន ជា អ្នកចេះជាង។ ពាក្យ ចេះបែបនេះ នាំ បែរ ជា មាន ន័យ

មួយថ្មី ដូច លោក ប៉ុន ចន្ទម៉ុល និយាយ ថា «គំនិត មាន តែអញ» ឬ «អញនិយម»។ ចេះ មុខវិជ្ជា ណាមួយ មិន មែន មាន សេចក្តី ថា ខ្លួនចេះ អ្វីៗ គ្រប់បែបយ៉ាង លើស អ្នកដទៃ នោះឡើយ។




# មរតក របស់ បញ្ញាខ្មែរ

បុព្វបុរសខ្មែរ បានទុក «មរតករបស់បញ្ញា» ច្រើន ឥតគគនា ដល់ កូនខ្មែរ។ មរតកនោះ មាន គ្រប់ផ្នែក ដូចជា អក្សរសាស្ត្រ អក្សរសិល្ប៍ ក្បួនច្បាប់គ្រប់បែបយ៉ាង សំរាប់ កូនខ្មែរ សម័យក្រោយ យក វា មក ធ្វើការពិចារណា ក្នុង ការរស់នៅ ជា រៀងរាល់ថ្ងៃ របស់ ខ្លួន និង សំរាប់ អានទុក ជា ការកំសាន្តអារម្មណ៍។ នៅចំពោះ ស្នាដៃ ដែល ប្រកប ទៅដោយ គុណភាព នៃ បញ្ញា នៃ បុព្វបុរសខ្មែរ ដ៏ច្រើន នោះ យើង ជា កូនខ្មែរ ជំនាន់ក្រោយ ហាក់ បី មាន ភាព ជា កុមារមួយ រស់ក្នុង ភាពងងឹតងងល់ លើ គំនរ សម្បត្តិ វប្បធម៌ជាតិ។ ពេលណា ខ្មែរយើង ស្គាល់តម្លៃ មរតក នៃ បញ្ញា ដែល មាន នៅក្នុង វប្បធម៌ជាតិយើង ច្បាស់ ជា នឹក យល់ដឹង អំពី តម្លៃ សាសន៍ជាតិ ក្នុង ចំណោមសាសន៍ ជាតិដ៏ទៃ មាន នៅក្នុង សង្គម មនុស្សជាតិ។

ខ្មែរ ពិតមែន តែ មាន បេតិភ័ណ្ឌជាតិ ប្រកប ទៅដោយ កិត្តិនាម ជា ច្រើន តែ ជា ប្រជាជាតិមួយ ធ្លាក់ខ្លួន ខ្ញុំគេ អស់ច្រើនសតវត្ស។ ថ្មីៗនេះ ស្រុកខ្មែរ ធ្លាក់ ក្នុង អាណានិគមយួន (១៩៧៩-១៩៨៩) ដែល ជា ការរលំជាតិ មួយ

ហួស នូវ ការនឹកស្មាន របស់ខ្មែរម្នាក់ៗ។ តើ ជា កំហុស នរណា ? ឬ ក៏ ជា កម្មវាសនា គេចមិនផុត របស់ជាតិ ខ្មែរ ? មោទនភាពខ្មែរ បាត់សាបសូន្យ ធ្វើ ឲ ខ្មែរ រស់នៅ តែ ក្នុងស្រមោល នៃ ភាពរុងរឿង ពី អតីតកាល និង ការ ចងគំនុំ ឬ ការតូចចិត្ត លើ វាសនា របស់ខ្លួន។ វិនាសកម្ម ថ្មីៗនេះ នាំ បន្ថែម ឲ វប្បធម៌ និង អារ្យធម៌ខ្មែរ រិតតែចុះ អន់ខ្សោយ បន្តទៅទៀត។ តែ ហាក់បី ដូច ជា គ្មាន នរណា ជា អ្នកទទួល ខុសត្រូវ នូវ ទុព្វលភាព ជា ប្រវត្តិ សាស្ត្រ នេះឡើយ ?

តែ យើង ត្រូវ យល់ដឹង ដែរ ថា មរតក នៃ វប្បធម៌ខ្មែរ មិន សុទ្ធតែ គំនិត វិជ្ជមាន សំរាប់ ការរស់នៅ របស់ខ្មែរ នៅ ក្នុង សម័យថ្មី ដែរ ដូច្នេះ ត្រូវចាំបាច់ យក មរតក នេះ មក ពិចារណា ដើម្បី អោយដឹង ថា អ្វី ជា គុណ ភាព និង គុណវិបត្តិ សំរាប់ សង្គមសម័យ។

លោក វ៉ាន់ ឌី កាអុន បញ្ញវន្តខ្មែរ មួយរូប បាន លើកយក មក ធ្វើការពិចារណា ឡើងវិញ នូវ គំនិត បុរាណខ្លះៗ ដែល ជា គំនិត សំរាប់ កាច់បំបាក់ ចិត្តគំនិតខ្មែរ ទុនខ្សោយ ឲ រស់នៅ ក្នុងផ្នត់គំនិត ជា អ្នកចេះគោរព អ្នកមានអំណាច

ឬ អ្នកប្រាជ្ញ។ អ្នកខ្លាំង ទាំងនោះ នាំ គ្នា តាក់តែង មេរៀនចរិយាសាស្ត្រ ឬ ដំបូន្មានផ្សេងៗ ដោយខ្លួនឯង សំរាប់ប្រយោជន៍ខ្លួនឯង។ ឧទាហរណ៍ មានដូចតទៅ៖

*ចូលស្ទឹងតាមបទ ចូលស្រុកតាមប្រទេស; ខ្លួនទាបកុំគោង ដៃខ្លីកុំយោងស្រវាឪបភ្នំ; ទំមិនធំជាងនាឡិ។ល។*

ក្នុង សង្គម កំពុង ចុះអន់ខ្សោយ ក្នុងផ្នែក គំនិត បញ្ញាវន្ត ត្រូវ មាន ភារកិច្ច យក គំនិត ចាញ់គេ ងើបមុខមិនរួច មក ធ្វើការពិចារណា ឡើងវិញ ដើម្បី ប្រឌិត គំនិតថ្មី សំរាប់ ឈ្នះគេ ដើម្បី ជាតិខ្លួន។

បើ ខ្មែរណា បាន អាន សៀវភៅ លោក ឃីន ហុកឌី មានជូន ឈ្មោះ ខាងលើ រួចមកហើយ ច្បាស់ ជា ធ្វើ ឲ អ្នកអាននោះ មាន មោទនភាព លើ ភោគទ្រព្យ វប្បធម៌ខ្មែរ។ តែភោគទ្រព្យនេះ នា បច្ចុប្បន្ន នេះ វា ស្ថិត នៅ តែ ក្នុងសារមន្ទីរ នៅ តែ ក្នុង សៀវភៅ និង នៅ ក្នុង តែ គំនិតអ្នកចេះដឹងខ្មែរ មួយចំនួនតូច វា រហូត ក្លាយ ទៅ ជា ស្រមោលគ្មាន សារៈប្រយោជន៍ អ្វីសោះ សំរាប់ ការរស់នៅ របស់ខ្មែរ។ ជា ពិសេស ទៅទៀត ដូច បានជំរាប ខាងលើរួចមក

ហើយ ខ្មែរយើង មាន ទម្លាប់ ទុក គំនិត វប្បធម៌ ជា វត្ថុ អរូប ជា វត្ថុ បន្ទាប់បន្សំ សំរាប់ជាតិ ដូច្នេះ ភោគទ្រព្យវប្បធម៌ ដែល ជា មរតកជាតិខ្មែរ វា គ្មាន តម្លៃ អ្វី លើស ក្រៅ តែ ជា តម្លៃនិមិត្តរូបតែប៉ុណ្ណោះ នៅក្នុងចិត្តគំនិតខ្មែរ។

ក្នុង អំឡុង ឆ្នាំ ១៨៩០ ពេល ដែល បារាំង ត្រួតខ្មែរ ដាច់មុខ គេ ឥតសូវយកចិត្តទុកដាក់ ធ្វើការស្រាវជ្រាវ ក្នុង ផ្នែក អក្សរសាស្ត្រ នោះប៉ុន្មានទេ។ ក្នុងចំណុច នេះ លោក ឃីន ហុកឌី[2] សរសេរ ក្នុង សៀវភៅ ថា៖ «*អ្នកប្រាជ្ញបារាំង គេ មិនបាន ធ្វើការស្រាវជ្រាវ អ្វី បានច្រើន លើ វិស័យ អក្សរសាស្ត្រខ្មែរនោះទេ ព្រោះ វិស័យនេះ មាន ទំហំធំវែង អន្លាយពេក ធ្វើ អោយ អ្នកស្រាវជ្រាវ បរទេស អស់សង្ឃឹម ព្រោះ ដើម្បី អាច សិក្សា អក្សរសាស្ត្របាន គឺ ត្រូវ រៀនភាសាខ្មែរ ឲ មាន ចំណេះ ខ្ពង់ខ្ពស់ ទើប យល់ អត្ថបទ ទាំងនោះ*»។

[2] ឃីន ហុកឌី : ទិដ្ឋភាព ទូទៅ នៃ អក្សរសាស្ត្រខ្មែរ- Edition L'Harmattan។

## បញ្ញាវន្តខ្មែរ ពី សម័យ អាណានិគម រហូត មកដល់ សម័យ ឯករាជ្យជាតិ

ក្នុង សម័យ ក្រោយអង្គរ (ពី ស.គ.ទី១៥ ដល់ ស.គ.ទី១៨) ស្រុកខ្មែរ បាន ធ្លាក់ ក្នុង អត្ថង្គត ហើយ អត្ថគត នេះ បាន បង្ហាញ ប្រព័ន្ធ នៃ គំនិតបញ្ញាខ្មែរ នាំ ឲ សង្គម ជាតិ រស់ ខ្វះ អាហារសតិ។ ផលវិបាក ជាក់ស្ដែង គឺ ការ ភ្លេច ប្រវត្តិសាស្ត្រជាតិ អស់រយៈពេល ជាង បី សតវត្ស។ ក្នុង រយៈពេល នោះ ជាតិខ្មែរ ទទួល ឥទ្ធិពល គ្រប់វិស័យ ពី ប្រទេសជិតខាង មាន សៀម និង យួន។ អ្វី ដែល ឆ្ងាញ់ អ្វី ដែលល្អ ខ្មែរ តែងតែ និយាយ ថា ជា របស់ សៀម ឬ យួន ជា និច្ច ឧទាហរណ៍៖ សម្លម្ជូរយួន នឹង ចំណីសៀម។ ល។ គំនិត ចៀមជាំ ដោយ មិនដឹងខ្លួន នេះ វា រស់នៅ ក្នុង សតិខ្មែរ ច្រើន សតវត្ស នាំ ឲ ខ្មែរ បាត់សេចក្ដី ទុកចិត្ត លើខ្លួនឯង ហើយ ដូរ ចរិយាសម្បត្តិ ពី ជនខ្ចីឃ្នាត ទៅជា ជនក្រអែស ក្នុង កិច្ចការសាធារណៈ។ ឧទាហរណ៍: ក្នុង ពាក្យពេជ្យ អស់សង្ឃឹម មួយនិយាយ ថា៖ «ខ្លួន មួយ មិនអាច ទូលផែនដី ម្នាក់ឯង បានទេ»

ក្នុងចរភាព នៃ **ចាតប័ត្រ**[3] នេះ បើក ឪកាស ឲ បរទេស គេ យក ទឹកដីខ្មែរ ដោយ មិនចាំបាច់ ខំប្រឹង អ្វីច្រើននោះ ឡើយ ព្រោះ គេ យល់ ថា ផ្លែឈើ ដល់ ទុំស្អុយ រលួយ គង់ តែ វា ជ្រុះខ្លួនឯង។ នៅក្នុង ចាតប័ត្រ មាន នៅក្នុង គតិខ្មែរ វា ក្លាយ ជា ពុម្ព នៃ ការអប់រំ របស់ខ្មែរ។ ជនជាតិមួយ ខ្វះ សេចក្តីសង្ឃឹម ក្នុងគតិ ទៅលើ អនាគត របស់ខ្លួន គឺ ជា ជាតិ រស់ចាំ តែស្លាប់ តែប៉ុណ្ណោះ។ កង្វះនេះ នាំ ឲ យើង សួរ ជា សំណួរ ថា តើ ជា ភាពបង្ហាញ នូវ «ភាវៈ មិនល្អ ជា ទូទៅ[4] នៃ មនុស្ស របស់ខ្មែរនោះឬ ? ឬ ជា កម្មពៀរ ព្រហ្ម លិខិត របស់ជនជាតិខ្មែរ ដែល ខ្មែរយើង តែងតែ និយាយ លេងប្រទ្បំ មែនថា៖ «ខ្លួនជាជាតិមានកម្ម» បាន ជាស្រុក ខ្មែរ មាន ឈ្មោះ ថា «កម្មពូជជា» ដែល ក្លាយ ជា ពាក្យ « កម្ពុជា»។ ក្នុង អំឡុង ជាងបីសតវត្ស ជនជាតិខ្មែរ មិន ត្រឹមតែ បាត់ ជំនឿលើ ខ្លួនឯងតែប៉ុណ្ណោះទេ គឺ ខ្មែរ បាត់ ថែមទៀត នូវ អ្វី ដែល ជា ចក្ខុនិមិត លើរូបភាព ទាំងមូល

---

[3] ចាតប័ត្រ= ការអត់ធ្មត់ ; Résignation
[4] ភាវៈមិនល្អជាទូទៅ= Mal-être général។

នៃប្រជាជាតិ របស់ខ្លួន ដោយហេតុ នេះ ខ្មែរ មើលឃើញរូបភាពស្រុក នៅក្នុង សម័យនោះ ត្រឹមតែស្រុក របស់ស្តេច ឬ មួយត្រឹមតែ ជា វត្ថុអ្វី មាន កម្មសិទ្ធិករ តែប៉ុណ្ណោះ។

ជនជាតិខ្មែរ ក្រោយ ពី បាន រស់នៅ អស់ច្រើន សតវត្ស ក្នុង ចាតប័ត្រ គ្រប់ប្រការមក ហើយ ដល់ មកចុង សតវត្ស ទី១៩ មាន រស្មីជោគ មួយ សើច រក ខ្មែរ គឺ « អាណាព្យាបាលបារាំង» នេះឯង។ តែ ខ្មែរយើង អាច ចោទសួរ ជា សំនួរ ថា សន្ធិសញ្ញាអាណាព្យាបាល នេះ (១៨៦៣) តើ ពិត ជា រនាំងទប់ មហិច្ឆិតា នៃ វិត្ថារកម្មទឹកដី របស់ ប្រទេស ជិតខាង មកលើ ស្រុកខ្មែរ បានដែរ ឬទេ ?

ការបើក ទំព័រ ថ្មីនេះ វា គ្រាន់តែ ជា «លាភ» សំរាប់ ខ្មែរ ដូច្នេះ សន្ធិសញ្ញាអាណាព្យាល បារាំង នេះ វា ជា ធាតុវិជ្ជមាន ផង អវិជ្ជមាន ផង ដូច្នេះ ស្ថាភាព នេះ តើ វា មាន អនុភាព អ្វីខ្លះ ដែរ មកលើ គតិ នៃ បញ្ញាវន្តខ្មែរ ?

## ១.គតិ ថ្មី នៃ បញ្ញាវន្តខ្មែរ

ការជួបប្រទះ ជា ដំបូង របស់ ប្រជាជាតិខ្មែរ ជា មួយនឹង វប្បធម៌ នៃ បស្ចឹមប្រទេស វា គ្មាន នាំ មក នូវ គំនិត អ្វី ដែល បស្ចឹម ប្រទេស គេ ទុក ជា **តម្លៃសជ្ឈនិកៈ**[5] របស់ សង្គមគេ គឺ «សេរីភាព» និង «សទ្ធិមនុស្ស»។ ត្រូវ យើង ដឹង ថា សទ្ធិសញ្ញាអាណាព្យាបាល បារាំង វា មាន ធាតុ ជា នយោបាយ និង យោធា ហើយ ក្នុងនោះ គ្មាន និយាយ អ្វី អំពី គតិ មនុស្សជាតិ នោះឡើយ។ ហត្ថលេខី ទាំងពីរ គ្មាន សមភាព នៃ កម្លាំង នោះឡើយ។ ជា សទ្ធិសញ្ញា រវាង អ្នកខ្លាំង ជា មួយនឹង អ្នកខ្សោយ ដែល អាច ឲ អ្នកខ្លាំង គេ ទាញ បាន ផលប្រយោជន៍ ពី អ្នកខ្សោយ បាន ងាយស្រួល។ តែ ទោះបី មាន សភាពការណ៍ អសមភាពបែប នេះ ក៏ដោយ ខ្មែរ អាច មាន ប្រយោជន៍ ពីរ យ៉ាងដែរ គឺ ៖ ការពារបូរណ ទឹកដីខ្មែរ ផ្នែក ខាងលិច និង ការកាត់ បន្ថយ ឥទ្ធិពល សៀម មកលើ មហាក្សត្រខ្មែរ។ អ្វីៗ ឯទៀត គឺ គ្រាន់ តែ ជា គ្រឿងតុបតែង លំអរ ផ្ទះខ្មែរ តែ

5 តម្លៃសជ្ឈនិកៈ= Valeur intrinsèque។

ប៉ុណ្ណោះ។ សទ្ធិសញ្ញា នេះ យើង អាច ចាត់ ទុក វា ជា «អំពើ អវិជ្ជមាន» តែ វា ជា អវិជ្ជមាន ចាំបាច់មួយ សំរាប់ សង្គ្រោះជាតិខ្មែរ ៗ គេចផុត បាន ពី វិនាសកម្ម កំណត់ ដោយ កម្មវាសនា ដែល ជាតិខ្មែរ កំពុងតែ ជួបប្រទះ នៅ ក្នុង សតវត្ស ទី១៩ គឺ ប្រទេសខ្មែរ កំពុង ប្រទេស សៀម និង យួន កាត់ចែកគ្នា ដោយ យក ទន្លេមេកុង ជា ព្រំដែនធម្មជាតិ។

អស់រយៈពេល ៩០ ឆ្នាំ (១៨៦៣-១៩៥៣) ស្រុកខ្មែរ រស់នៅ ក្រោម របប អាណានិគមបារាំង មាន ទិស នយោបាយ ច្បាស់លាស់ សំរាប់ អនុវត្តន៏ ផែនការ អាណានិគម ដែល មាន នៅក្នុង គំនិត លោក Jules Ferry (១៨៣២-១៨៩៣) ជា បញ្ញាវន្ត នាយករដ្ឋមន្ត្រី សំភី ក្នុង នយោបាយ អាណានិគម ដោយ ប្រើ ទស្សនៈ «បេសកកម្ម អារ្យធម្មូប ណីយកម្ម នៃ ប្រទេសអាណានិគម»។ ទស្សនះនេះ ជា មូល ដ្ឋាន នៃ ការបង្កើត រូបិ បញ្ញាថ្មី របស់ខ្មែរ ក្នុងនោះ មាន វិទ្យាស្សង្ស ជា សេចក្តី សំអាង នូវ ឧត្តមភាព របស់អ្នក អាណានិគមនិយម។ ក្នុងរយៈពេល ៩០ ឆ្នាំ ប្រទេសខ្មែរ បានក្លាយ ជា ភូមិ មួយ របស់ ប្រទេសបារាំង នៅក្នុង ភូមិ

នេះ យុវជនខ្មែរ បាន ទទួល ការអប់រំ តាម កម្មវិធី របស់ អ្នកអាណានិគមនិយម តាំ ពីកុមារភាព ក្នុង ផ្នែកវិទ្យាសាស្ត្រ។ តែ យើងដឹង ថា វិទ្យាសាស្ត្រ គ្រាន់ តែ ជា ឧបករណ៍ នៃ គំនិត សំរាប់ ធ្វើ ឲ បាន សម្រេច នូវ គោលបំណង របស់ គំនិត តែប៉ុណ្ណោះ។ អវត្តមាន នៃ ការឲតម្លៃ នៃ បុព្វបញ្ញាខ្មែរ ក្នុង កម្មវិធីសិក្សាថ្មី នាំ ឲ មាន ការផ្ដាច់ ចំណេះថ្មី ពី មូលដ្ឋាន ជាតិខ្មែរ ដែល ធ្វើ អោយ វិទ្យាសាស្ត្រ ស្ថិត នៅ ត្រឹមតែ ជា ចំណេះវិជ្ជា សំរាប់ វណ្ណៈ ច្រើនជាង ជា វិជ្ជា បំភ្លឺ ការចេះដឹង របស់បុគ្គល។ តែ សេចក្ដីសន្និដ្ឋាន រហ័យ បែបនេះ វា អាច នាំ អោយ មាន ការយល់ច្រឡំ ដែរ បើ គ្មាន ការពិចារណា អំពី ការអប់រំខ្មែរ ពី សម័យដើម។

## ការអប់រំ នៅក្នុង សម័យអង្គរ

សង្គម មនុស្សលោកនិមួយៗ អាច ក្លាយ ជា ប្រជាជាតិ បាន សុទ្ធ តែ មាន បញ្ញាជាតិ ជា ថាមវន្ត។ ក្នុង ចំណុច នេះឯង ដែល យើង ចង់ លើកមក ពិចារណា អំពី របៀប អប់រំខ្មែរ មុន សម័យបារាំង ចូលស្រុកខ្មែរ ដើម្បី ទុក ជា

យោង សំរាប់ សំគាល់ នៃ ដំណើរជឿនលឿន នៃ បញ្ញាខ្មែរ មាន នៅក្នុង សម័យអាណានិគម។

ការអប់រំ ក្នុង សម័យអង្គរ ដូច យើង បាន ជំរាប ជា សង្ខេប ខាងលើ រួចខ្លះ មកហើយ ជា ការអប់រំ នៃ វណ្ណៈ។ អ្នក ដែល បាន ទទួល ការអប់រំ ក្នុង សម័យ នោះ គឺ ជា បុគ្គល កើត នៅ ក្នុង វណ្ណៈព្រាហ្មណ៍ ឬ វណ្ណៈក្សត្រ។ ដូច្នេះ ការចេះដឹង ជា បុព្វសិទ្ធ នៃ វណ្ណៈ។ ក្នុង កម្មវិធី អប់រំ សំរាប់ វណ្ណៈព្រាហ្មណ៍ គឺ សិក្សា អំពី លទ្ធិព្រហ្មញ្ញ សាសនា ឯចំណែក វណ្ណៈ ក្សត្រ មាន កាតព្វកិច្ចសិក្សា វិជ្ជា ដឹកនាំជាតិ ដែល មាន នៅក្នុង លទ្ធិព្រហ្មញ្ញ សាសនា។ វណ្ណៈ ទាំង ពីរ នេះឯង ជា វណ្ណៈ នៃ វរភាពជាតិ[6] វណ្ណៈទី១ ក្នុង ផ្នែកគំនិត រីឯ វណ្ណៈទី២ ក្នុងផ្នែកនយោបាយដឹកនាំជាតិ។ ឯចំណែក ប្រជារាស្ត្រ ទទួល បាន ការអប់រំ ក្នុង ផ្នែក វិជ្ជាជីវៈ នៅក្នុង ចង្កុំ គ្រួសារ។ ផ្លូវ ចូល ទៅ ក្នុង មជ្ឈដ្ឋាន នៃ ការអប់រំ របស់ វណ្ណៈព្រាហ្មណ៍ និង ក្សត្រ:

[6] វណ្ណៈវរភាពជាតិ= Classe élite nationale។

គឺ បិទជិត មិន អាចចូលបាន នោះឡើយ។ ចំពោះ ព្រហ្មញ្ញសាសនា ការបែងចែក វណ្ណៈនេះ ជា គោលការណ៍ សំរាប់ រក្សា សុខដុម ក្នុង សង្គម ឬ ជា ការចែក មុខនាទី ដល់ វណ្ណៈនិមួយៗ ក្នុង ការរក សុខតមកម្ម[7] ក្នុង សង្គម មនុស្សផង និង សង្គម ជាតិ ផង ដែល ពួក ព្រាហ្មណ៍ ទុក ជា អសមភាព ដើម្បី អាណាប្រយោជន៍។

ក្នុង របៀប អប់រំ នៃ វណ្ណៈ បែបនេះ បង្កើត ឲ មាន បញ្ញាវន្ត មាន វណ្ណៈ មាន ឋានៈ ជា អ្នកចេះដឹង ផង ជា ឧត្តមមនុស្សផង ដែល ជា ជន មាន បុព្វសិទ្ធិ ពី កំណើត មាន កាតព្វកិច្ច ទទួល មរតក នៃ ចំណេះ របស់ វណ្ណៈ ដែល ខ្លួន ជា សមាជិកសិទ្ធិ[8]។ បញ្ញាវន្ត មាន វណ្ណៈ នេះឯង ជា ក្រុមអ្នក កសាង វប្បធម៌ រុងរឿង ជាតិខ្មែរ និង មហានគរខ្មែរ មាន ឈ្មោះល្បីល្បាញ ច្រើន សតវត្ស នៅក្នុង ដំបន់ អាស៊ីបែក អគ្នេយ៍។ ដូច្នេះ គេ អាចទុក បាន ថា ព្រហ្មញ្ញសាសនា នៅក្នុង សម័យអង្គរ ជា ឃ្លាំង នៃ ចំណេះ របស់

---

[7] សុខតមកម្ម= Harmonisation។
[8] សមាជិកជាសិទ្ធិ= Membre de droit។

បញ្ញាវន្តខ្មែរ ចង ប្រទាក់ ឆ្វាត់គ្នា ជា បណ្ដាញ នៃ ការ អភិវឌ្ឍន៍ ប្រទេសខ្មែរ ឲ ក្លាយ ជា មហានគរ វប្បធម៌ ផង និង មហានគរ យោធា ផង។ វរជនខ្មែរ នៅក្នុង សម័យអង្គរ ត្រូវ មាន លក្ខណៈ ជា អ្នកចេះដឹង ផង ជា មេទ័ព ផង និង ជា អភិបាល ផង ហើយ មាន ទំនាក់ទំនង រវាង គ្នា នឹង គ្នា ជា អង្គកាយ នៃ គតិ និង ជា បណ្ដាញ នៃ ក្រុម សមគំនិត រួមរស់ ជា មួយគ្នា ដើម្បី ការពារ ប្រយោជន៍ វណ្ណៈ ជា អ្នកចេះដឹង និង ជា អ្នកដឹកនាំ ជាតិ។ ហេតុនេះឯង គេ ឃើញ មាន ការរួបរួម រវាង វណ្ណៈព្រាហ្មណ៍ ជា មួយ វណ្ណៈក្សត្រ រួម ជា វណ្ណៈ បញ្ញាវន្ត ក្នុង លក្ខណៈ ជា ទំនាក់ទំនង ចាំបាច់ ដើម្បី រក្សា អជ្យោត្តមភាព[9] នៃ វណ្ណៈ ទាំង ពីរ លើ វណ្ណៈ ដទៃទៀត ក្នុង ឋានៈ ខ្លួន ជា អ្នកបង្វឹក និង ជា ម្ចាស់ នៃ អំណាចជាតិ។ យើង អាច សន្និដ្ឋាន បាន ថា ការអប់រំ នៅក្នុង សម័យអង្គរ មាន គោលបំណង មិនត្រឹមតែ ជា ការផ្ទេរ ចំណេះ ពី គ្រូ ដល់

[9] អជ្យោត្តមភាព= Suprématie ; ភាពឧត្តមបំផុត។

សិស្ស តែប៉ុណ្ណោះនោះឡើយ វា មាន លើស ពី ការនេះ ទៅទៀត គឺ ជា ការបណ្តុះបញ្ញា អោយដុះ នៅក្នុង គតិ របស់សិស្ស ដឹងយល់ អំពី សិទ្ធិ និង ករណីយកិច្ច របស់ខ្លួន ជាបញ្ញាវន្ត។

## ការអប់រំ នៅក្នុង ពុទ្ធសម័យ ឬ ក្នុង សម័យក្រោយអង្គរ

នៅក្នុង សម័យពុទ្ធសាសនា ការអប់រំ មាន គោលដៅ ខុសពី សម័យអង្គរ និយម ព្រាហ្មណ៍សាសនា ព្រោះ ទ្រឹស្តី ព្រាហ្មណ៍សាសនា វា ខុស ដោយឡែក ពី ទ្រឹស្តី ពុទ្ធសាសនា។ នៅក្នុងសម័យ ព្រាហ្មណ៍សាសនា ជា ការអប់រំ នៃ វរជន[10] រីឯនៅក្នុង សម័យ ពុទ្ធសាសនា ជា ការអប់រំ នៃ មហាជន[11] ។ នៅតាម វត្តអារាម យុវ័នខ្មែរ ដែល មាតា បិតា បញ្ជូន ទៅនៅ ក្តី (ទៅនៅវត្ត) បួសនេន ដោយមាន ភិក្ខុសង្ឃ ជា គ្រូបង្រៀន អោយចេះដឹង សេចក្តីខុសត្រូវរាក់ជ្រៅ គឺ ទទួលការអប់រំ មូលដ្ឋាន គឺ រៀន អក្សរខ្មែរ បន្ទាប់មក មាន ការ

---

10 អប់រំនៃវរជន= Formation d’élite។
11 អប់រំមហាជន= Formation de masse។

អប់រំសាសនា គឺ រៀន អក្សរបាលី ជាន់ទាប[12] ដើម្បី រៀន សូត្រធម៌ និង សីលធម៌ អោយ ស្គាល់ សេវនភាព ក្នុង ជីវិត រស់នៅ។ នៅពេលចប់ ដំណាក់ការនេះ យុវ័ន ណា ចេះ សរសេរ និង អាន អក្សរខ្មែរ និង ចេះ សូត្រធម៌ មួយជំពូក មាន ជម្រើសស្បាន់ ដោយ ខ្លួនឯង សូម បន្ត បួស ជា ភិក្ខុសង្ឃ បំរើ សាសនា។ ចំណែក យុវ័ន ណា មិនចង់ បន្ត បួស ជន នោះ លាចាក ស្បង់ ត្រឡប់ ទៅ រស់នៅ ជា មនុស្សធម្មតា តែ អ្នកផងទាំងពួក គេ អោយ ឈ្មោះ ថា បណ្ឌិត ព្រោះ មនុស្ស នោះ ចេះ ធម៌សាសនា ស្គាល់ សីលធម៌ ជា មនុស្ស ដឹងក្តី គឺ ជា មនុស្ស បានរៀនសូត្រ នៅវត្តអារាម។ ពាក្យ បណ្ឌិត នោះ លុះចំណេរមក ក៏បាន ក្លាយ ជា ពាក្យ អន្ទិត ដែល សំដៅ លើ មនុស្សចេះដឹង ធម្មតា តែ មិនមាន លក្ខណ៍ ជា អ្នកប្រាជ្ញ។ ក្នុងចំណោម ពិក្ខុសង្ឃ, បណ្ឌិត និង អន្ទិត ទាំងនោះ ក្លាយ ជា អ្នកនិពន្ធ, កវី, ប្រវត្តិករ, គន្ថរចនាចារ្យ[13] ទុក ស្នាដៃ ពិស្សុត ជាច្រើន អោយ កូនខ្មែរ

[12] ជាន់ទាប = Rudimentaire។
[13] គន្ថរចនាចារ្យ : écrivain moraliste។

ជំនាន់ក្រោយ តែ ភាគច្រើន មិន បញ្ចេញ ឈ្មោះ ព្រោះ ខ្លាច មាន ទំនាស់ ជា មួយ អំណាច អ្នកដឹកនាំ។ អ្នក ទាំង នោះហើយ ជា បញ្ញវន្ត នៅក្នុង អត្ថន័យ នៃ និយមន័យ នៃ ពាក្យ បញ្ញវន្ត។

តែ ការអប់រំ ទាំង ពីរ នោះ គ្មាន គោលការណ៍ ជា ការអប់រំ ជាតិ នោះឡើយ ព្រោះ គ្មាន កម្មវិធីជាតិ សំរាប់ អប់រំ យុវជន អោយ មាន ឧត្តមគតិជាតិ ព្រោះ នៅ សម័យ នោះ ខ្លឹមសារជាតិ វា មាន កំរឹត ត្រឹមតែ បុគ្គល ព្រះមហាក្សត្រ តែប៉ុណ្ណោះ៖ ការពារជាតិ គឺ ការពារ ព្រះមហាក្សត្រ; ក្បត់ ជាតិ គឺ ក្បត់ ព្រះមហាក្សត្រ នោះឯង។




## វប្បដ្ឋាន

វប្បដ្ឋាន[14] នៃ គំនិតជាតិ គឺ ការអប់រំជាតិ។ អប់រំជាតិ គឺ អប់រំយុវជន និង ប្រជាជន អោយ ស្គាល់ គ្រឹះ នៃ ជាតិ ដូច មាន អត្តសញ្ញាណ របស់ ជាតិ, ចំណេះចេះដឹង និង គោល ដៅ របស់ ជាតិ។

**អត្តសញ្ញាណរបស់ជាតិ** មាន ប្រវត្តិសាស្រ្តជាតិ, ភាសាជាតិ និងវប្បធម៌ជាតិ។

**ចំណេះចេះដឹង** សំរាប់ ការរស់នៅ ដូច មាន ចំណេះ ទូទៅ, ចំណេះ អាជីព និង បញ្ញាភា។

**គោលដៅរបស់ជាតិ** មាន សុភមង្គល និង សុខុមាលភាព នៃប្រជាពលរដ្ឋ រស់នៅ នៅក្នុង សង្គម ប្រកបដោយ សន្តិភាព មាន បាវចៈនាជាតិ ជា បាត គឺ សមភាព ភាតរភាព សេរីភាពលទ្ធិប្រជាធិបតេយ្យ និង អភិវឌ្ឍន៍ជាតិ។

[14] វប្បដ្ឋាន ; កន្លែងសាបព្រោះ; ថ្នាល។

ការអប់រំជាតិ ជាបេសកកម្ម សំខាន់ របស់រដ្ឋ។ រដ្ឋ-ប្រជាជាតិ ជា ជ័យជំនះ របស់រដ្ឋ លើ អនាធិបតេយ្យ រួច មាន ការវិវត្តន៍ មកដល់ នីតិរដ្ឋ គឺ ជោគជ័យ ច្បាប់ លើ ទុរុបយោគ (abus) គ្រប់ បែបយ៉ាង។ ពី តំណាក់ការ ទី១ ទៅ តំណាក់ការ ទី២ វា មាន ការអប់រំ នៃ ចំណេះ ដល់ មនុស្សលោក ជា យាន ជា បឋម ចំណេះ អំពី ធម្មជាតិ បន្ទាប់ មក អំពី ជំនឿសាសនា ក្រោយ មក ទៀត អំពី ទស្សនវិជ្ជា ទី បញ្ចប់ គឺ ចំណេះវិទ្យាសាស្ត្រ។ នៅ មស្ជឹមប្រទេស សម័យ ពន្លឺបញ្ញា នៅ សតវត្សទី១៧ ធ្វើ អោយ មាន ការកែប្រែ នៃ ចក្ខុវិស័យ លើ សង្គមមនុស្ស ដែល នាំ អោយ មនុស្ស ម្នាក់ៗ មាន សម្បជញ្ញៈ អំពី អត្តភាព នៃ សេរីភាព របស់ ខ្លួន ជា នរជាតិ អាច មាន លទ្ធភាព ដើរ តួ ជា នាដការ នៃ ការរីកចំរើន សំរាប់ ខ្លួនឯង ផង និង មនុស្សជាតិ ផង។ ចាប់ ពី ពេលនោះ មក សំរាប់ មនុស្ស ទស្សនវិជ្ជា និង វិទ្យាសាស្ត្រ ក្លាយ ជា បញ្ញាប្រតិបត្តិ (intelligence pratique) មាន ប្រយោជន៍ សំរាប់ ការរស់នៅ របស់ មនុស្ស ដូចយ៉ាង ការពិចារណា ដេញរកហេតុផល និង ការអនុវត្តន៍ នៃ ចំណេះ វិទ្យាសាស្ត្រ នៅក្នុង ការរស់នៅ គ្រប់ វិស័យ របស់

មនុស្ស។ ការរីកចំរើន នៃ បច្ចេកទេស ដូចយ៉ាង សម្ភារៈ សំរាប់ បោះពុម្ព ជា យាន សំរាប់ ផ្សាយ បាន ចំនួន ច្រើន នៃ ចំណេះ ហៅ បាន ថា ប្រជាធិបតេយ្យរូបនីយកម្ម នៃ ការ ចេះដឹង ដែលជា ការលើក កំរិត នៃ ការចេះដឹង របស់ ប្រជាពលរដ្ឋ។ ការពិចារណា រកហេតុផល ជា គំនិត បំបាត់ នូវ អបិយជំនឿ ដែលជា ជំនឿ ទុក ឲ ប្រជាករ ល្ងង់; ជា មធ្យោបាយ ស្វែង រក ការពិត សំរាប់ ការរស់នៅ។ ទស្សនវិជ្ជា នេះឯង ដែល ជា ប្រភព នៃសីលធម៌ នៃ សង្គម ដែល មាន សារជាតិ ខុស ពី ធម៌ នៃ សាសនា។ សីលធម៌ នៃ សង្គម ជា ក្រមនីតិ រវាង សមាជិក នៃ សង្គម (convention entre les membres de la société) សំរាប់ ការរស់នៅ ជាមួយគ្នា អោយ បាន សមរម្យ នៅក្នុង សង្គម ដែល ទុក តម្លៃ នៃ នរជាតិ ជា ខ្លឹម របស់ សង្គម។ រីឯ ធម៌ នៃ សាសនា វិញ ជា ទិដ្ឋិ (dogme) មាន ក្បួន ព្រះ សំរាប់ ប្រតិបត្តិ ដាច់ខាត ជា មុខបាទ[15] តាម ពិធី ច្បាស់លាស់

15 មុខបាទ ; devoir personnel។

ដើម្បី ទទួល បុណ្យ ជា គុណស្រ័យ និង កំចាត់ បាប ជា ការ រំដោះ ទុក្ខ។

យើងដឹង ថា វប្បដ្ឋាន នៃ បញ្ញាខ្មែរ គឺ ធម៌ សាសនា លាយ គ្នា រវាង ព្រហ្មញ្ញសាសនា នឹង ពុទ្ធសាសនា។ ទោះបី ពុទ្ធសាសនា មាន វិសិដ្ឋភាព លើ ព្រហ្មញ្ញសាសនា ក្រោយ សម័យអង្គរ តែ នៅក្នុង បញ្ញាប្រតិបត្តិខ្មែរ នៅមាន ស្នាម នៃ ឥទ្ធិពល របស់ ព្រហ្មញ្ញសាសនា ជា និច្ច ដូចយ៉ាង ខ្មែរ យើង ទុក ការបន់ស្រន់ សូម សេចក្ដីសុខ ពី ព្រះ ឬ ទេវតា ជា អំពើ សំខាន់ ក្នុង ការរស់នៅ។ វប្បដ្ឋាន នៃ បញ្ញាខ្មែរ មួយទៀត គឺ ដើមកំណើត នៃ ប្រជាជាតិខ្មែរ ជា ប្រជាជាតិ កើត ពី អំណាច ព្រះមហាក្សត្រ; ព្រះអង្គ ជា កម្មសិទ្ធិករ ឬ ម្ចាស់ នៃ ទឹកដី នគរ និង ប្រជារាស្ត្រ។ វប្បដ្ឋាន ទាំងពីរ នេះហើយ សូន ផ្នត់គំនិតខ្មែរ ជា គំនិត លុះក្នុងអំណាចគេ (l’esprit soumis) ដើម្បី រស់ សន្សំ សុខ ដល់ អាត្មា។ លុះ ចំណេរមក ផ្នត់គំនិត នេះ បង្កើត ជា វប្បធម៌ កម្មផល យល់ព្រម ទទួលរង អ្វី ជា ទុក្ខ ជា កម្ម របស់ខ្លួន។ យក ចា តប័ត្រ ជា មាគ៌ាអកម្ម សំរាប់ សង្គ្រោះ គឺ រង់ចាំ ដំណោះ ស្រាយ កើត ពី ក្រៅ ចិត្តខ្លួនឯង គឺថា ពឹង អ្នក ដទៃ ដូច

ខ្មែរយើង នាំគ្នា រង់ចាំ ស្រកោក (en vain) ក្នុង ទុរសុបិន ព្រះបាទ ធម្មិក ចុះ ពី ឋានសួគ៌ មក សង្គ្រោះ ទុក្ខ គ្រប់ យ៉ាង របស់ខ្លួន។ អកម្មភាព នោះ មិនបង្កើត បញ្ញា មាបនកម្ម[16] នាំគ្នា រស់ នៅក្នុង ទម្លាប់ ជា បញ្ញា ត្រាប់[17] ពី ទំនាន់ មួយ ទៅ ទំនាន់ មួយ នាំអោយ សមូហបញ្ញា[18] ក្រិន ធ្វើអោយ សង្គម គ្មាន បុនភាវកម្ម ឬ កែជាថ្មី ឬ សើរើ នូវ អ្វី ដែល ជា អវិជ្ជមាន សំរាប់ សង្គម។ តែ មាន ជនខ្មែរ ជា ច្រើនណាស់ដែរ មាន ចំណេះ ជា អ្នកប្រាជ្ញ ជា សទ្ធាមុះមុត (ferveur) សំរាប់ ជាតិ តែ មិនច្រើនល្មម ជា ឫទ្ធានុភាព សំរាប់ ធ្វើ ជា ចលករ រុញ ប្រជាជាតិ អោយក្លាយ ជា សង្គម សម័យ ដើម្បី ធ្វើការប្រកួត លើ ឆាក អន្តរជាតិ និង នៅ ក្នុង ដំបន់ របស់ខ្លួន។ សមូហបញ្ញាខ្មែរ បញ្ចប់ ជវនៈ (élan) ចាប់ ពី សតវត្ស ទី១៥ រហូត មកដល់ បច្ចុប្បន្ន ព្រោះ ខ្វះ វប្បដ្ឋានថ្មី សំរាប់ បណ្តុះ បញ្ញាជាតិ ដោយសារ ជាតិខ្មែរ រស់

[16] បញ្ញា មាបនកម្ម ; intelligence créative។
[17] បញ្ញា ត្រាប់ ; intelligence imitative។
[18] សមូហបញ្ញា ; intelligence collective។

នៅក្រោម ឥទ្ធិពល ប្រទេស ជិតខាង ដែល គេ មាន ឆន្ទៈ មាន គោលវិធី ដើម្បី រំលាយ ជាតិសាសន៍ខ្មែរ។ ចលករ ពុទ្ធសាសនា ក្តី រាជានិយម ក្តី ដែល ខ្មែរ តែងតែទុក ជា វប្បដ្ឋាន នៃ កម្លាំងជាតិ តាំង ម៉ាស៊ិន បញ្ញា ស្ថិតនៅ ជា មរតក និច្ចល សំរាប់ តែ ខ្មែរ យកមក រំឭក ប្រកបដោយ ការខកចិត្ត ក្រៃលែង នៅក្នុង ជីវិតភាព នៃ ការរស់នៅ របស់ខ្លួន។

មួយវិញទៀត វប្បដ្ឋាន អាណានិគមបារាំង សំរាប់ ដាំ ការ ចេះដឹងសម័យខ្មែរ តាម របៀប វិទ្យាសាស្ត្រ វា គ្មាន ពលវសទ្ធា (ferveur) គ្រប់គ្រាន់ សំរាប់ កសាង គ្រិះ បញ្ញា ជា ថ្មី ពេលក្រោយ ប្រជាជាតិ ធ្លាក់ក្នុង អត្ថង្គត ច្រើន សតវត្ស។ ប្រជាជាតិខ្មែរ ចាប់ពី សតវត្ស ទី១៩ មក ហាក់បីដូច ជា មនុស្ស ងើបពីឈឺ ត្រូវការ ថ្នាំកម្លាំង ដើម្បី អោយ សព៌ាង្គកាយ និង បញ្ញា អាចមាន ថាមពល និង សុជី ឡើងវិញ។ នៅអំឡុងពេល ដ៏ខ្លីមួយ តែប៉ុណ្ណោះ ដែល ប្រជាជាតិខ្មែរ ស្គាល់ សន្តិភាព ក្នុង របប អាណានិគម និង បន្ទាប់ ពីទទួលបាន ឯករាជ្យ ពេញលេញ មាន ពេលវេលា អាច នឹង មាន លទ្ធភាព រៀបចំ សង្គមជាតិ គ្រប់វិស័យ សំរាប់ អនុ

វត្ត នយោបាយ អភិវឌ្ឍន៍ បែរ ជា សព សម្តេច សីហនុ ជ្រើសរើសយក វិធីសាស្ត្រ សេដ្ឋកិច្ច សង្គមនិយម ដែលនាំ អោយ ការអភិវឌ្ឍន៍ សេដ្ឋកិច្ចជាតិ មាន ដំណើរ យឺត បំផុត ក្នុងចំណោម ប្រទេស នៅ ក្នុង ដំបន់ អាស៊ី ភាគ អគ្នេយ៍ សូម្បី ប្រទេស វៀតណាម ដែល មាន សង្គ្រាម ក៏មាន អត្រា អភិវឌ្ឍន៍ សេដ្ឋកិច្ច ខ្ពស់ ជាង ប្រទេសខ្មែរ ដែរ។ មិន តែ ប៉ុណ្ណោះ ការអនុញ្ញាត របស់ សម្តេច សីហនុ អោយ ទ័ព យួនកុម្មុនិស្ត ប្រើ ទឹកដីខ្មែរ សំរាប់ ធ្វើ សង្គ្រាម នៅ ស្រុក យួន នាំ ភ្លើងសង្គ្រាម ចូលមកក្នុង ស្រុកខ្មែរ ចាប់ពី ទសវត្សរ៍ ៧០ មក។ វិបត្តិ សំខាន់ ហ្នេះ ធ្វើអោយអាក់ខាន គ្រប់ ទម្រង់ នៃ អភិវឌ្ឍន៍ជាតិ។ គួរកត់ សំគាល់ ថា របប សង្គមនិយម មិន អនុញ្ញាត អោយ យុវជន ចេញទៅ មស្វឹមប្រទេស ដើម្បី បន្ត ឧត្តមសិក្សា ដែល នាំ យុវជនខ្មែរ មាន កំរិតចេះដឹង ទាប បំផុត នៅក្នុងចំណោម យុវជន អាស៊ី។

បច្ចុប្បន្ន ហ្នេះ នៅស្រុកខ្មែរ មាន ដុះ មហាវិទ្យាល័យ ឯកជន ថ្នាក់អន្តរជាតិ ដូច ផ្សិត តែ មិនសំរាប់ យុវជន ទាំងអស់នោះឡើយ ព្រោះ យុវ័ន ភាគច្រើន ជា កូន អ្នកក្រ

មាតាបិតា គ្មាន មធ្យោបាយហិរញ្ញវត្ថុ សំរាប់ អោយ កូនបន្តសិក្សា ថ្នាក់មធ្យម និង ឧត្តម។ ស្ថានភាព ហ្នឹះ បង្កើតជា វណ្ណៈ រវាង យុវជន ដែល ជា វប្បដ្ឋាន ដាំ វិសមធម៌ សំរាប់ សង្គម អោយ តម្លៃ លើតែ តម្លៃ ទឹកប្រាក់។ ក្នុងសង្គមបែបនេះ ឧបមា បើ កើត ជា កូន កម្មករ គឺ ច្បាស់ ជា នឹងក្លាយបន្ត ជា កម្មករ ជា ដាច់ខាត។ ឧបនិស្ស័យ នឹងអាចចេញ ពី ស្ថានភាព ក្រលំបាក ដែល មាន ពី កំណើត គឺសឹងតែ សូន្យ ព្រោះ ប្រព័ន្ធ សិក្សាធិការជាតិ មិន បើកអោយ យុវ័ន អភ័ព្វទ្រព្យ មាន លាភជ័យ អាច ចេញរួច ពី ទលិទ្ទភាព (pauvreté) តាម បញ្ញាខ្លួន។ ប្រព័ន្ធ សិក្សាធិការជាតិ បែបនេះ គឺ ជា ម៉ាស៊ិន ផលិត វណ្ណៈ អ្នកចេះដឹង និងសង្គម ទុកឲប្រជាកររល្ងង់។ នៅស្រុកខ្មែរ សព្វថ្ងៃ មានបណ្ឌិត ជា ច្រើន មាន ព្រឹទ្ធបណ្ឌិតជាតិ ហើយ ពួក អ្នកដឹកនាំ សុទ្ធ ជា មាន ងារ ជា បណ្ឌិតជាតិ តែ យើងអាចសួរ ជា សំណួរ ថា តើ បណ្ឌិត ទាំងឡាយនោះ គាត់ មានស្មារតី ជា បញ្ញាវន្ត ដែរឬទេ ?

---

**និពន្ធ ដោយ ឧប សៅ សង្ហា**
**២០១៥ (អត្ថបទ ពិនិត្យ និង សរសេរ ឡើងវិញ នៅ ឆ្នាំ ២០១៧)**




# ប្រភេទ នៃ បញ្ញាវន្តខ្មែរ

ទីនេះ យើង សាកល្បង យក អក្សរសិល្ប៍ខ្មែរ មក ធ្វើ ជាគោល ដើម្បី ឆ្លុះមើល អត្តភាព នៃ បញ្ញាវ័ន្តខ្មែរ មាន នៅក្នុង ប្រវត្តិសាស្ត្រជាតិ។ គេ ដឹង ថា នៅក្នុង លោកនេះ យុគនិមួយៗ វា មាន កម្លាំងចលករ របស់វា ដូចយ៉ាង នៅក្នុងសម័យដើម មាន កម្លាំង សាសនា បន្ទាប់មក មាន កម្លាំងវិចារណញ្ញាណ បន្តមកទៀត មាន កម្លាំង វិទ្យាសាស្ត្រ ហើយកម្លាំង ចលករ និមួយៗ សុទ្ធ តែ មាន ប្រយោជន៏ ដល់មនុស្សជាតិ។ សាសនា ធ្វើការអប់រំ មនុស្ស អោយ ស្គាល់កុសល និង អកុសល; វិចារណញ្ញាណ នាំ មនុស្សលោក ស្គាល់នូវ នរតម្លៃ (valeur humaine); វិទ្យាសាស្ត្រ បើក បញ្ញាមនុស្សលោក ដើម្បី ស្វែងរក សុខុមាលភាព នៃ មនុស្សលោក។ បច្ចុប្បន្នកាល ជា យុគ ដែល មនុស្សលោក ជា អ្នកទទួលខុសត្រូវ ផ្ទាល់ លើ អ្វី ដែល ខ្លួន បង្កើត អោយមាន។ គឺ ជា យុគ នៃ ការទទួលខុសត្រូវរួម ដែល វា បង្កើត នូវ សណ្តាប់ធ្នាប់ ពិភពលោក ថ្មី (nouvel ordre mondial) ឈរលើ ការទទួលខុសត្រូវ នៃ រដ្ឋ និមួយៗ ចំពោះ នរតម្លៃ។

សង្គមខ្មែរ ហូរតាម ចរន្ត នៃ យុគ ទាំងឡាយ ដែល បានរៀបរាប់ ដូច ខាងលើនេះ។ មនុស្សខ្មែរ មាន ចិត្តនាការ (pensée) ជា ចលនាគំនិត បង្កើត ជា បញ្ញាប្រតិបត្តិ ផង

និង បញ្ញាឧត្តមគតិ[19] ផង។ អក្សរសិល្ប៍ខ្មែរ អាចនឹង ឆ្លុះឃើញ បញ្ញាខ្មែរ ដែល យើង លើកយកមក សាកល្បង ពិចារណា នៅខាងក្រោមនេះ។

អក្សរសិល្ប៍ ជា វិទ្យាស្ស្រ ដែល ចោទ និង ដោះស្រាយ បញ្ហា មនុស្ស ដោយ សិល្ប៍វិធី ទៅតាម សង្គមនិមួយៗ។ ទោះបី អក្សរសិល្ប៍ខ្មែរ មានតិចតួចតក្តី តែ វា មាន ចរិតលក្ខណៈ សំខាន់ អាច ឲ យល់ដឹង ច្បាស់ ពិតប្រាកដ អំពី តួនាទី របស់ខ្លួន ដែល អាចទុក ជា ជំនួយ សំរាប់ បំភ្លឺ ឲឃើញ ថា អ្វី ជា លក្ខណៈពិសេស របស់ខ្មែរ តែ វា ក៏បង្ហាញ ឲឃើញដែរ នូវ ការមិនគ្រប់គ្រាន់ របស់ខ្លួនឯង ជា ពិសេស លើ សេចក្តី អះអាង ថា ខ្លួន ជា ជិពវិញ្ញាតិ[20] នៃ សង្គមខ្មែរ ហើយ នៅពេល ដែល ខ្លួន ក្លាយ ជា វិទ្យាស្ស្រ សិល្បវិជ្ជា នៃ បញ្ហា មនុស្ស ចាប់ ពី ពាក់កណ្តាល សតវត្ស ទី២០ មក។

នៅ បស្ចិមប្រទេស ពាក្យ «អក្សរសិល្ប៍» ចាប់ផ្តើម មាន អត្ថន័យសម័យ ក្នុង មជ្ឈដ្ឋាន នៃ វរជន នៅក្នុង សតវត្ស ទី១៨ តែប៉ុណ្ណោះ ព្រោះ សៀវភៅ ជា ផលិតផល កម្រ រក បាន មាន តម្លៃ ថ្លៃណាស់ ហើយ ទុក សម្រាប់ តែ ក្រុម

---

19 បញ្ញាឧត្តមគតិ ; intelligence idéologique។
20 ជិពវិញ្ញាតិ ; expression vivante។

បញ្ញវន្តអក្សរសាស្ត្រ និង អ្នកប្រាជ្ញ។ មកដល់ សតវត្ស ទី១៩ អក្សរសិល្ប៍ ចាប់ផ្តើម មាន វិត្ថារកម្ម ឥទ្ធិពល ក្នុង មជ្ឈដ្ឋាន សាធារណជន ដោយសារ មាន ការចំរើនលូត លាស់ យ៉ាងច្រើន នៅក្នុង វិស័យ សិក្សាសាធារណ។ ហេតុ នេះហើយ បាន ជា សៀវភៅ ក្លាយ ជា ផលិតផល ធម្មតា សំរាប់ សាធារណជន ទោះបី នៅ មាន តម្លៃ ថ្លៃនៅឡើយ។ អ្នកអានសៀវភៅ មិនចាប់ មាន ឋានៈ ជា បញ្ញវន្ត ឬ អ្នកប្រាជ្ញ ដូច សតវត្ស មុននោះឡើយ ; នរណាម្នាក់ ក៏អាច អានសៀវភៅបាន បើ គេ ចេះអក្សរ និង មាន គំនិត ចង់ ដឹង ចង់យល់ អំពី អ្វី ដែល សសេរ នៅក្នុង សៀវភៅ។ សតវត្សទី១៩ ជាការចាប់ផ្តើម នូវ ប្រជាវូបនីយកម្ម នៃ ការ អានសៀវភៅ។

មាន សៀវភៅ គឺ ត្រូវមាន អ្នកសសេរ ហើយ អ្នកសសេរ ច្រើនមាន គតិសេរី សំរាប់ សសេរ គំនិត របស់ខ្លួន ព្រោះ សេរីភាព ជា គំនិត សំខាន់ នៃ ការត្រិះរិះ របស់ មនុស្ស។ ហេតុនេះឯងហើយ បានជា អ្នកកាន់អំណាច នៅក្នុង សម័យបុរាណ តែងតែ មាន ការបារម្ភ ចំពោះ ឥទ្ធិពល និង ស្អប់ខ្ពើម អក្សរសិល្ប៍ ព្រោះ វា ច្រើនតែ បង្កើត ទំនាស់ ប្រឆាំងនឹង ប្រពន្ធនយោបាយ។ អក្សរសិល្ប៍ តាមធម្មតា តែងតែ ធ្វើ អោយ រញ្ជួយ ប្រព័ន្ធ នយោបាយ ដែល ជា ប្រព័ន្ធ យក ជំនឿ ឥត សមហេតុផល មក ធ្វើ ជា យុត្តិកម្ម

នៃ អំណាចរបស់ខ្លួន និង ជា ប្រព័ន្ធ បង្កើតឡើង សំរាប់ រក្សា បុព្វសិទ្ធិ វណ្ណៈ អ្នកដឹកនាំ។ ឆន្ទៈ របស់ អក្សរសិល្ប៍ គឺ ពិនិត្យ និង អង្រួន ចុះនាម ក្នុង គោលបំណង ធ្វើការកែ ទម្រង់ លំដាប់ចាស់ ដើម្បី សុខុមាលភាព នៃមនុស្សលោក និង មនុស្សជាតិ។

គេ ស្គាល់ អក្សរសិល្ប៍ខ្មែរ តិចជាង សិល្បៈខ្មែរ ទោះបី មាន កំណើត ក្នុង ពេលវេលា ជាមួយ គ្នាក្តី។ គ្រប់ មហាក្សត្យស្ថាបនិក មហានគរខ្មែរ ព្រះអង្គ បាន ចារទុក អត្ថបទ ជាច្រើន លើ ផ្ទាំង ប្រាសាទ លើ ស្លឹកត្នោត ជា ហូរហែ បន្តគ្នា មាន នៅក្នុង មហារយៈពេល នៃ ប្រវត្តិសាស្ត្រខ្មែរ ដែល ជា ការបញ្ជាក់ នូវ អត្ថិភាព នៃ អក្សរសិល្ប៍ខ្មែរ ទោះបី អក្សរសិល្ប៍ ទាំងឡាយនោះ គ្មាន រូបបី ជា ទិស្សមាន[21] ដូច មហាប្រាសាទអង្គរ ដែល ទាក់ទាញ អារម្មណ៍ អ្នកសិក្សាវិជ្ជា ខាងបូព៌ាប្រទេស តែ ចំណារ ដែល មាន ចារទុក ជា ទូទៅនោះ អាច ជា ជំនួយ សំរាប់ បភ្លឺនូវប្រវត្តិ

[21] ។ទិស្សមាន= អាចមើលឃើញ ; visible

សាស្ត្រ វប្បធម៌ និង អារ្យធម៌ ខ្មែរ បាន ដូច រូបភាព នៃ ប្រាសាទ នោះដែរ។

ហេតុដូច្នេះ មន្ទិល អំពី អត្ថិភាព នៃ អក្សរសិល្ប៍ខ្មែរ ទុក ជា មោឃភាព។ តែ បញ្ហា នៅ មាន ចោទ គឺ ស្ថិត នៅលើ សំណួរ សួរ ថា តើ អក្សរសិល្ប៍ខ្មែរ ជា វិទ្យាសាស្ត្រ ដែរ ឬទេ ដែល មាន ចារ ទុកក្នុង ប្រវត្តិសាស្ត្រ របស់ ខ្លួន។ តែ ប្រវត្តិសាស្ត្រ នៃ អក្សរសិល្ប៍ខ្មែរ ជា វិទ្យាសាស្ត្រ មិនដូច ជា វិទ្យាសាស្ត្រ ដែល គេ យកមក សិក្សា នៅ មស្ទីមប្រទេស នោះឡើយ។ ហើយចុះបើ វិទ្យាសាស្ត្រ នៃ អក្សរសិល្ប៍នេះ ទៀត ទើប តែ ចាប់ផ្ដើម មាន ក្រោយ កំណើត នៃ អត្ថបទ ចំណេរ រឿងនិទាន រឿងព្រេង កំណាព្យ អណ្ដែតអណ្ដូង អត្ថបទ ជា ឧបទេស រឿង ល្ខោន ប្រលោមលោក សសេរ សាកល្បង មាន លក្ខណៈ ជា សាសនា ក្ដី ជា ទស្សនវិជ្ជា ក្ដី បញ្ចេញ ឲដឹង នូវ មនោសញ្ចេញនា របស់ខ្មែរ តាំង ពី យូរ យារ មកហើយ សួរថា ការចង់ដឹង អំពី អក្សរសិល្ប៍ខ្មែរ ជា វិទ្យាសាស្ត្រ មានសារប្រយោជន៍អ្វី ?

ប្រយោជន៍ គឺ ថិតនៅលើ ការសិក្សា ឲ យល់ដឹងអំពីតម្លៃ នៃ អក្សរសិល្ប៍ តាម វិទ្យាសាស្ត្រ នោះឯង។ ជា ការងាយ ស្រួល ក្នុង ការសិក្សា អំពី អក្សរសិល្ប៍ខ្មែរ តាម ការបង្ហាញ

នូវ ទ្រង់ទ្រាយ ជា ការសង្ខេប ឬ ជា គ្រោងរាង ដូច ជា ធ្វើ ការរៀបរាប់ ជា ឈុត នាម នៃ សៀវភៅ ជា ឈ្មោះ នៃ អ្នក និពន្ធ ជា ប្រធានបទសិក្សា។ តែ ការបង្ហាញ បែបនេះនៅ តែ មិន មាន ភាពទូលំទូលាយ ស្មើនឹង រូបថត បង្ហាញ ប្រាសាទ នានា នៅអង្គរ។ ដូច្នេះ មាន តែ ចំណេះ ជា វិទ្យា សង្ស និង សិក្សា រិះគន់ អត្ថបទ ទើប អាច បង្ហាញ ប្រភព ដើម និង តម្លៃ នៃ អក្សរសិល្ប៍ខ្មែរ បាន។ តម្លៃ នេះហើយ ដែល អាច ឆ្លុះ មើល បញ្ញាខ្មែរ គឺ ចលនាគំនិត[22] នៃ បញ្ញា វន្តខ្មែរ។

លោក ឃីន ហុកឌី សរសេរ នៅក្នុងសៀវភៅ របស់លោក បែងចែក អក្សរសាស្ត្រខ្មែរ ជា ច្រើន ប្រភេទ និង យុគៈ សិលាចារិក, អក្សរសាស្ត្រ សម័យ កណ្ដាល, គម្ពីរ, អក្សរ សាស្ត្រ ពុទ្ធសាសនា, អក្សរសាស្ត្រ ប្រវត្តិសាស្ត្រ, អក្សរសាស្ត្រ បច្ចេកទេស, អក្សរសាស្ត្រ ប្រដៅ, ល្បែង, រឿង ព្រេង, រឿក ថា, ល្បើក អង្គរវត្ត, រឿង រាមកេរ្តិ៍, អក្សរសាស្ត្រ ទំនើប, ប្រលោមលោក។ ស្នាដៃ ទាំងឡាយនោះ សុទ្ធតែមាន អ្នក

[22] ចលនាគំនិត ; courant de pensée។

សរសេរ ក្នុង ចលនាគំនិត ច្បាស់លាស់ សំរាប់បង្ហាញ ដល់ អ្នកអាន។ អ្នកនិពន្ធ ទាំងនោះ ជា បញ្ញាវន្ត មាន ដែន គំនិត ពិតប្រាកដ មាន វត្ថុវិស័យ ពិស្តារ[23] ជា ចលនា គំនិត ប្រាថ្នា[24] នៅក្នុង សម័យ ដែល ខ្លួន កំពុង រស់នៅ សំរាប់ ប្រយោជន៍ បញ្ញា។ បើ គេ បានអាន អក្សរសិល្ប៍ ឬ អក្សរសាស្ត្រខ្មែរ គេ អាច បែងចែក ជា បី ប្រភេទ គំនិតៈ អក្សរសិល្ប៍ ឧត្តមគតិ (littérature idéologique) អក្សរសិល្ប៍ សាសនា (littérature religieuse) និង អក្សរសិល្ប៍ សាមញ្ញ (littérature vulgaire) ដែល អាចអោយគេ សន្និដ្ឋានបាន ថា វា មាន នៅក្នុង សង្គមខ្មែរ បញ្ញាវន្ត ឧត្តមគតិ បញ្ញាវន្ត សាសនា និង បញ្ញាវន្ត សាមញ្ញ ដូចនៅ បស្ចឹមប្រទេសដែរ។

គេដឹង ថា ការវិវត្តន៍ នៃ សង្គម វា ធ្វើអោយ គំនិតដើរ ទៅរក សុក្រឹតភាព ដែល ជា កត្តា បង្កើន និង ពង្រឹង បញ្ញា នៃ មនុស្សលោក។ នៅ សម័យអង្គរ ឬ មហានគរ បញ្ញាខ្មែរ បានដល់ កំរិតខ្ពស់បំផុត។ ចំណារ លើ សិលាចារិក នៅក្នុង

[23] វត្ថុវិស័យ ពិស្តារ ; objectif précise។
[24] ចលនាគំនិត ប្រាថ្នា ; courant de pensée voulu។

សម័យនោះ ច្រើន មាន លក្ខណៈ ជា គុណកថា និង ជា ស្តុតិ (éloge) ដល់ ព្រះមហាក្សត្រ ព្រោះ មហានគរ ត្រូវចាំបាច់ មាន ឧត្តមគតិជាតិ ដ៏ ខ្ពង់ខ្ពស់ សំរាប់ ធ្វើ ជា គ្រឹះជាតិ។ ឧត្តមគតិជាតិ នេះឯង ជា ស្តំ មួយ ក្នុង ចំណោម ស្តំ ដទៃ ទៀត ដូចយ៉ាង មហាក្សត្រ កងទ័ព និង សាសនា សំរាប់ ទ្រទ្រង់ មហិទ្ធានុភាព នៃ មហានគរ។ ដូច្នេះ សម័យ អង្គរ មិនមែន គ្រាន់តែ ជា មហានគរ យោធា តែប៉ុណ្ណោះទេ គឺ ជា មហានគរ បញ្ញា មាន បញ្ញាវន្ត ឧត្តមគតិ សរសេរ ឧត្តមគតិជាតិ ផ្សាយ ជា សាធារណៈ ដើម្បី ពង្រឹង ព្រលឹង ស្មារតីជាតិ។ ឧទាហរណ៍ មួយចំនួន នៃ ចំណារ ដែល ជា និមិត្តរូប នៃ ឧត្តមគតិជាតិ ដែល ជា ចិត្តនាការ ប្រកប ទៅដោយ ការពិចារណា របស់ អ្នកនិព័ន្ធ៖

« ទុក្ខប្រជារាស្ត្រ ជា ទុក្ខ របស់ ព្រះមហាក្សត្រ »

« អាណាប្រជានុរាស្ត្រព្រះអង្គ លុងទឹក ក្នុង មហាសាគរ ដ៏ មាន ជម្រៅ ឥត អាច ឆ្លងបាន និង គួរខ្លាច ដូច រស់នៅ ក្នុង ទុក្ខ កាល ជា កាលីយុគ តែនៅ ពេល ដែល រាស្ត្រ បាន មកជួបព្រះអង្គ ដែល ជា ត្រើយដ៏ឧត្តម រាស្ត្រ បាន រក ឃើញ ឡើងវិញ នូវ សេចក្តីសង្ឃឹម ថ្មី (បន្ទាយស្រី) »

« ព្រះអង្គ កំទេចកាលី ដែល ជា ជន មាន សង្ស៊ឹម ថា ខ្លួន អាច ប្រព្រឹត្ត បទឧក្រិដ្ឋ ឈ្លប មើល ជា និច្ច គ្រប់ ចំណុច ខ្សោយ ដែល មាន កើតឡើង ក្នុង នគរ...(ថ្នល់បារាយ) »

« ដី លិច ក្នុង មហាសាគរ នៃ បាបធម៌ ព្រះអង្គ ជា អ្នកស ង្គ្រោះ មនុស្ស ឲ រួចចេញ ពី បាបធម៌នេះ...(អង្គរវត្ត) »

« ទោះបី ជើង នៅសល់ តែមួយគត់ ហើយ ត្រូវកាលី កំពុង វាយ បំបាក់ឲអស់ តែ គោបា យក ផលធម្ម របស់ ព្រះរាជា ជា ពំនឹង ដូច ជា សសរ មាំ អស្ចារ្យ ឲខ្លួន អាច ឈរ ជាប់ មាំទាំ ដូច ខ្លួន នៅ មាន ជើងបួន ដើម្បី សួរ ពិរុទ្ធ នឹង ការ វាត់វែធ របស់កាលី (សិលាចារិកហង់ជៃ) »

« គារវ ភក្តី ដល់ ឧត្តមសច្ចៈ ប្រៀបបាននឹង វេហា ដែល បាន រំដោះ ទុក្ខ បីយ៉ាង របស់ សត្វលោក ដើម្បី ពាក់ ជា ថ្មី នូវ សេរីរៈ បី មាន ធម្មាកាយា សេចក្តី ត្រេកត្រអាល កាយា និង ការប្រែប្រួលកាយា (សិលាចារិក នៅ ភ្នំបន្ទាយណង) »

នៅក្នុង សម័យ កណ្តាល (សតវត្ស ទី១៥ ដល់ ដើម សតវត្ស ទី ១៩) អ្នកស្រាវជ្រៀវ ខាងផ្នែក អក្សរសាស្ត្រ រកឃើញ អត្ថ បទ អក្សរសាស្ត្រ ជា ច្រើន ពាន់ក្បាល៖ មាន អក្សរសាស្ត្រ ពុទ្ធសាសនា ឬ ព្រះ ត្រៃបិដក, អក្សរសាស្ត្រ ប្រវត្តិសាស្ត្រ ឬ

របាកក្សត្រ, អក្សរសាស្ត្រ បច្ចេកទេស ឬ ក្រម - ក្បួន - តម្រា, សុភាសិត, ច្បាប់, រឿង ព្រេង, រឿង ល្បែង, វីរកថា[25] (ដើម្បី ចង់ដឹង ពិស្តា លើ ចំណុច នេះ សូម អាន សៀវភៅ លោក ឃីន ហុកឌី - ទិដ្ឋភាព ទូទៅ នៃ អក្សរសាស្ត្រខ្មែរ)។ ទោះបី នៅក្នុង សម័យ កណ្ដាល ស្រុកខ្មែរ ជួប ប្រទះ នូវ វិបត្តិ គ្រប់ បែប យ៉ាង ដែល អាច ចាត់ ទុក ជា សម័យ

---

25 វីរកថា ជា ពាក្យ បង្កើតថ្មី សំរាប់ កត់ ត្រា ទស្សនះ ថ្មី វិជ្ជា ថ្មី... ដែល យើង ហៅ ថា « ពាក្យ វប្បធម៌ »។ វីរកថា មាន ន័យ ថា ជា « ស្នា ដៃ យ៉ាង ច្រើន វែង រៀប រៀង ឡើង ជា ពាក្យ កាព្យ និយាយ ពី សកម្មភាព ផ្សងព្រេង ដ៏ ស្វិតស្វាញ ក្លាហាន អង់អាច នៃ វីរបុរស មាន តួអង្គ ពោធិសត្វ ឬ ទេវៈ ឬ តួអង្គ ក្សត្រ៏ ខ្លាំង ពូកែ ក្នុង ការ ផ្ចាញ់ យក្ស មារ សត្រូវ ដើម្បី រំដោះ ទុក្ខ សោក របស់ មនុស្ស ជាតិ ឬ រំដោះ គូ សង្សារ ជា ដើម។ ឧទាហរណ៏ មហាភារតៈ, រាមាយណៈ, រាមកេរ្តិ៍ខ្មែរ ឬ អ៊ីលីយ៉ាត និង អូឌីសេ ជនជាតិ ក្រិច ជា ដើម។

អត្ថង្គតជាតិ តែ កវីខ្មែរ នាំគ្នា សរសេរ អត្ថបទ អក្សរសាស្ត្រ ជា ច្រើន សំរាប់ ទុក ជា ស្មារតីជាតិ។

នៅ ក្នុង ប្រភព ដ៏ ច្រើននេះ ហើយ នៅ ដែល អាច អោយ អ្នកនិព័ន្ធ ខ្មែរ សំដែង បាន នូវ ទេពកោសល ផ្ទាល់ខ្លួន។ តាម យោបល់ លោក កេង វាន់សាក់[26] តម្លៃ នៃ អក្សរសិល្ប៍ខ្មែរ អាច មាន ចម្លើយ បាន តាម ការ វាយ តម្លៃ អោយ ច្បាស់អំពី ភាពក្លៀវក្លា នូវ ការចាក់គ្រឹះ នៃ វប្បធម៌ មន-ខ្មែរ ដែល ទុក ជា ទម្រ និង ថាមពលខ្មែរ សំរាប់ ពង្រិក វប្បធម៌ និង សង្គម ខ្មែរ។ ពិតមែន តែ ប្រភព ភាសា សំស្ក្រឹត បាលី ថៃ និង ចិន, ឈ្មោះ តួអង្គ ក្នុង រឿង រាមាយាណា ឬ ជាតាកាស (ប្រវត្តិ នៃ ជាតិព្រះពុទ្ធ) ដូច ប្រធានបទ ដកស្រងចេញ មកពី អក្សសិល្ប៍ពុទ្ធិក ដែរ, អ្វី ដែល បាន រៀបរាប់ មកនេះ ដែល នាំ អោយ អ្នកប្រាជ្ញ ជា ច្រើន ធ្វើ សេចក្តី សន្និដ្ឋាន យ៉ាង រហ័ស ក្នុងបំណង ដាច់ថ្លៃ ថា អក្សរសិល្ប៍ខ្មែរ ក្លាយ មក ពី អក្សរសិល្ប៍ បរទេស។

[26] Quelques aspects de la littérature khmère – Faculté des Lettres er des Sciences Humaines de Phnom-Penh – 1966.

វា គ្មាន អ្វី ជា ការមិនល្អ ដែល អារ្យធម៌ ធំៗ ដកស្រង់យក ប្រធានបទ មាន រួមគ្នា ពី អារ្យធម៌ ដទៃទៀត មក ធ្វើ សំយោគ ជា មួយនឹង ប្រធានបទ របស់ខ្លួន ព្រោះ អក្សរសិល្ប៍ នៃ គ្រប់ ជាតិសាសន៍ ចាំង បង្ហាញ និង សម្រួល នៃ ការជ្រៀតជ្រែក រវាង ចរន្ត នៃ អារ្យធម៌។ តែ សារៈសំខាន់ មិន ស្ថិត នៅលើ កម្មវិធី ប្រធានបទ អ្វីមួយ ដែល គ្រប់ ជាតិសាសន៍ ទុក ជា សម្បត្តិរួម យក វា មក ធ្វើ «ជាតូបនីយកម្ម» តាម វិធី សមានកម្ម ឬ ផ្លាស់ ទ្រង់ទ្រាយ ជា ថ្មី យ៉ាង ជម្រៅ អស់រយៈពេល យូរអង្វែង ហើយ បន្ត ជា ថ្មី មិន ចេះចប់។

ការប្រែប្រួល នេះ ជា ការបង្កើត ចរិក ពិសេស និង តួអង្គ ផ្ទាល់ របស់ អារ្យធម៌ និមួយៗ។ កំណើត នេះ គឺ ជា លទ្ធផល នៃ អភិក្រម នៃ ឥទ្ធិពល នៃ សមានកម្ម និង សមិទ្ធិកម្ម ជា ថ្មី ៖ ខុស ពី គំរូចាស់ ដែល ក្លាយ ជា ជិពវិញ្ញាតិ នៃ ទេកោសល្បជាតិ។ ការណ៍ ទាំង នេះ ឯងហើយ ដែល មាន កើត ឡើង នៅក្នុង អក្សរសិល្ប៍ខ្មែរ ដែល បាន រំលាយ បាន នូវ គំរូចាស់ តួអង្គ និង ប្រធានបទ ជា កម្មវិធី ដើម្បី ធ្វើ អ្វី មួយ ថ្មី អោយ មាន ប្រភេទ ជា ខ្មែរ។

ដូច្នេះ រឿង រាមាយាណា ឥណ្ឌា បាន ក្លាយ ជា រឿងរាមកេរ្តិ៍ខ្មែរ ហើយ ទោះ បី ចំណងជើង សៀភៅ តួអង្គ និង ទីកន្លែង នៅ រក្សារ ហិរហៀង នូវ ឈ្មោះ ឥណ្ឌា នៅឡើយ តែ ថា អន្តរវត្ថុ វិញ មិន ដូចគ្នា ទាល់ តែ សោះនឹង ស្នាដៃ របស់ អ្នកនិពន្ធ វាលម៉ិគី (Valmiki) នោះឡើយ។ អត្ថបទ ទី១ នៃ រឿងរាមកេរ្តិ៍ខ្មែរ មិន បាន បង្ហាញ ឲ យើញ នូវ ការបកប្រែ ការគ្រាប់តាម ការយក លំនាំ តាម នៃ អត្ថបទ ឥណ្ឌា សោះ ឡើយ តែ ស្នាដៃខ្មែរ ជា ទម្រង់ ក្តី ជា គ្រិះក្តី ឃើញ មាន ភាព ផ្ទុយ ពី ស្នាដៃ រាមាយាណា (Ramayana) ឥណ្ឌាទៅវិញ។

ក្នុង សង្គមខ្មែរ គ្មាន មាន វណ្ណៈព្រាហ្មណ៍ ដើម្បី ការពារ មនោគមវិជ្ជា វណ្ណៈព្រាហ្មណ៍ ហើយ នៅ ក្នុងរឿង រាមាយាណា មាន ព្រះ រាមា ចុះ ពី ឋានសួគ៍ មក ការពារ មនោគមវិជ្ជា រួច យាង ត្រឡប់ ទៅ ឋាន ព្រះអង្គវិញ។ ដូច្នេះ រឿងរាមកេរ្តិ៍ខ្មែរ ប្រែ ព្រះ អោយ ក្លាយ ជា មនុស្ស រស់នៅ យ៉ាង មាំ ជា មនុស្ស នៅក្នុង សាន់វ័ណ្ណ នូវ បដិវាទកម្ម មាន នៅ ក្នុង សង្គម និង ប្រេមាការ ។ ស្នាដៃខ្មែរ ចាំង បង្ហាញ នូវ ទំនាស់ រវាង ព្រហ្មញ្ញសាសនា ជា មួយ ពុទ្ធសាសនា នៅក្នុង សម័យ អង្គរ ដែល មាន អ្នកគាំទ្រ ពុទ្ធសាសនា ប្រឆាំងនឹង ព្រហ្មញ្ញសាសនា។

នៅ ចំពោះមុខ អក្សរសិល្ប៍ ពុទ្ធសាសនា ការប្រែប្រួល គ្មាន លក្ខណៈ ដាច់ ខាន នោះឡើយ។ ទោះ ជា យ៉ាងណា រឿង ជាតក ខ្លះ ខ្មែរ មិន ទទួលយល់ព្រម ព្រោះ ទម្រង់ និង គ្រឹះ សាច់រឿង វា មិន សមស្រប តាម លក្ខណៈ ប្រពៃណី និង គំនិត ដើមខ្មែរ។

ដូចគ្នានឹង ការផ្លាស់ ទ្រង់ទ្រាយ ជា ថ្មី មាន មូលដ្ឋាន ខ្មែរូបនីយកម្ម ក្នុង វិស័យ អក្សរសិល្ប៍ សិល្បៈនិង ភាសា ដែល ធ្វើឡើង តាម និន្នាការ សំខាន់ ពីរ យ៉ាង នៃ អារ្យធម៌ខ្មែរ ៖ ប្រាកដនិយម និង សនិទាននិយម ។ និន្នាការ ទាំងពីរ នេះឯង នៅក្នុង រឿង រាមកេរ្តិ៍ខ្មែរ ដែល អ្នកនិព័ន្ធខ្មែរ យក មក ធ្វើ វិធី មនុស្ស រូបនីណកម្ម នៃ អាទិទេព រាមា អោយ ក្លាយ ជា មនុស្ស ឥត លំអៀង។

ពីព្រោះ អក្សរសិល្ប៍ខ្មែរ មាន តួអង្គ ជា ច្រើន ជា តួអង្គ មិនពិត ដូច ជា ទេវតា យក្ស ខ្មោច រុក្ខជាតិ សត្វ ចេះ និយាយ ភាសា មនុស្ស ដែល ខ្មែរ  យល់ ឃើញ ជា ទម្លាប់ ក្នុង ចរិត ជា ក្មេង ជា អច្ឆរិយ ឬ បញ្ឆោត លេង។ តែ បើ យើង យក អត្ថបទ មកសិក្សា រកការពិត យើង ឃើញ ថា ទេវតា ក្តី តួអង្គ ព្រះពុទ្ធ ក្នុង ជាតិមុនៗ ព្រះអង្គ ក្តី គឺ ជា មនុស្ស ពិត ប្រាកដ ណាស់។ ហើយ នៅក្នុង រឿងព្រេង

នានា មាន តួអង្គ ជា សត្វ ជា ច្រើន តែ តួអង្គ និមួយៗ ជា បុគ្គល សង្គម ដូចគ្នានឹង មនុស្ស នោះដែរ។

ហើយ ខ្មែរ ស្អប់ បំផុត គឺ ការ ឲ តម្លៃ សំខាន់ ទៅ លើ មនោសញ្ញេញនា  ភាពវិសេសវិសាល  និង របស់ គ្មាន ខ្លឹមសារ ដែល ពិបាកយល់។ អាទិទេព តែ មួយគត់ ដែល ខ្មែររាប់អាន គោរព យូរ ជាង គេ ទាំងអស់ គឺ សីលាលឹង្គ ព្រះឥសូរ ឯ ចំណែក អាទិទេព រាមា ដែល ជា អវតា ព្រះវិស្ណុខ្មែរ តែងតែ ទុក ជា មនុស្សា រស់នៅ ក្នុង ច្រវាក់ ទុក្ខ របស់ មនុស្ស មិន ចេះ ចប់ ដូច មនុស្សលោក។

ខណៈ ពេល ដែល អាទិទេព ក្លាយ ជា មនុស្ស ហើយ  វិរបុរស វិសេសវិសាល នាំ មកវិញ នូវ ធម្មជាតិ ពិត របស់ខ្លួន ដូចយ៉ាង ជា៖ មនុស្ស កំសាក អំនួត ពិបាកយល់ ឧទាហរណ៏៖

បុរស គង់-ហ៊ាន ជា វិរបុរស វិសេសវិសាល តែ មាន ធម្មជាតិ ជា មនុស្ស នៅ ចំពោះ មុខ គ្រោះថ្នាក់ គាត់ រាកអាចម៍ លើ ក្បាល សមិតដំរី ដែល ខ្លួន កំពុងជិះ ដំរី នោះ ដើម្បីធ្វើ ឲ ជ្រុះអាចម៍ ពី លើ ក្បាល វា បោល សំដៅ ទៅ រក ទ័ពសត្រូវ។ ឃើញ ដូច្នេះ នឹក ស្មាន តែ បុរស គង់-ហ៊ាន បញ្ជោ ឲ ដំរីសឹក បោល ចូល វាយ សំរុក នាំ គ្នា ភិតភ័យ រត់ ប្រសេកប្រសាច បោល ជួរទ័ព។ ទង្វើ នេះ នាំឲ គង់-ហ៊ាន ជា

ឧត្តមសេនីយ មាន ជ័យជំនះ លើ សត្រូវ ហើយ បាន ទទួល រង្វាន់ ជា ច្រើន ពី ព្រះមហាក្សត្យខ្លួន។ តាម ការពិត បុរស គង់-ហ៊ាន ជា មនុស្ស កម្លាច បំផុត តែ ជា ថៃដន្យ ទទួល បាន ជ័យជំនះ លើ សត្រូវ ក្នុង ភាពខ្លាំង ពូកែ ជា វិរបុរស។

ដូច ការស្វែង ភាព ដាច់ខាត ឋិតថេរ ចិរកាល ក្នុង សេចក្តី ស្រឡាញ់ នូវ ការមិនទៀងទាត់។ នៅក្នុង រឿង ជាតិព្រះពុទ្ធ ចំនួន ៥០ រឿង ដែល ខ្មែរ យក មក ធ្វើ ខ្មែរូបនីយកម្មគេ ឃើញ មាន លក្ខណៈ ជា រឿង ផ្សងព្រេង រឿង ស្នេហា របស់ មនុស្ស ជា ច្រើន ដែល មិន អាច រាប់បាន ជាង រឿង ស្តី ពី និព្វាន របស់ព្រះពុទ្ធ។ ក្នុង រឿង ទាំងឡាយ នោះ មាន រឿង ព្រះពុទ្ធ ជា វិរបុរស ប្រកបដោយ សោកនាដកម្ម ឬ ប្រកបដោយ អាថ៌កំបាំង មិន នាំ ឲ ខ្មែរ យកចិត្ត ទុកដាក់ ហើយ ក៏ មិន យកមក ទុកជា សករៈ នោះផង។ ជាតិព្រះពុទ្ធ ជា ទស្សនវិទូ ជា អ្នកតស៊ូ ប្រឆាំងនឹង អ្នកកាន់សាសនាជេន និង ព្រហ្មញ្ញសាសនា ខ្មែរ គ្រាន់ តែ យក មក សិក្សារ តែ មិន មាន ប្រជាប្រិយភាព នោះទេ។ រឿង តែ មួយគត់ ដែល ខ្មែរយើង ចូលចិត្ត គឺ រឿង មហាវេស្សន្តរ ជាតក ព្រោះ ជា រឿង បង្ហាញ នូវ បដិវាទកម្ម រវាង ការ

ស្វែងរក សុក្រឹតភាព និង កាតព្វកិច្ច សង្គម គ្រួសារ និង មនោសញ្ចេតនា។

បើ ខ្មែរ ទទួលស្គាល់ បញ្ញា មាន នៅក្នុង រឿង មហាជាតក ថា មាន តម្លៃ ខ្ពស់បំផុត គឺ នៅ លើ បញ្ញា ប្រតិបត្តិ និង ប្រាកដនិយម ដែល ធ្វើ មិន ឲ សត្រូវ ក្រៅ ឬ ក្នុង ក្ដី អាច មាន ជ័យជំនះបាន ហើយ ជា ពិសេស នៅត្រង់ ថា បញ្ញា នេះ ជា សម្ភារៈ ការពារ ដ៏ ប្រសើរ និង ជា ជាតិស្ថាបនកម្ម។

ហេតុដូច្នេះឯង ក្នុងចំណោម ១០ ជាតក ដែល ខ្មែរ យក មកធ្វើ ខ្មែរូបនីយកម្ម មានតែ រឿង មហាវេស្សន្តរជាតក និង មហាជាតក នេះ ឯង ជា ពិសេស រឿងទី១ តាម របៀប បកស្រាយខ្មែរ បាន អោយ សារៈសំខាន់ ទៅ លើ ភាព គួរ ឲ សង្វេក។ ហើយ ចំណុច ដែល ខ្មែរ ចូលចិត្ត បំផុត គឺ ព្រះវេស្សន្ត ធ្វើ បញ្ជ័យ កូន ទាំងពីរ និង ភរិយា រួច ហើយ ព្រះអង្គ បដិសេធ មិន ព្រម ទៅ រស់ សោយសុខ ឯកោ នៅ ឋានសួគ៏ សុខចិត្ត បន្ត រស់ នៅក្នុង ឋាន មនុស្ស ដើម្បី បន្ត ដាក់ទាន ព្រោះថា នៅ ឋានសួគ៏ ព្រះ អង្គ មិន អាច ធ្វើ ទាន បានឡើយ ព្រោះ គ្មាន នរណា ត្រូវ ការកុសល។

ហេតុដូច្នេះហើយ បាន ជា នៅក្នុង របៀប បកស្រាយខ្មែរ គេ ឃើញ ថា ពួក អាទិទេព មាន នៅក្នុង រឿងតណ្ហា ត្រូវ ខ្មែរ យក មក ធ្វើ ខ្មែរូបនីយកម្ម។ តាម ភាព ប្រាកដនិយម ជា វិចារណញ្ញាណ នេះ ទៀត គេ ឃើញ មាន ដែរ នៅ ក្នុង អត្ថបទ អក្សរសិល្ប៍ខ្មែរ សមិទ្ធិកម្ម ខាង ចម្លាក់ ខាង ស្ថាបត្យកម្ម ដែល មាន ទំនង ជា អាច់កំបាំង។

តែ ប្រាកដនិយមខ្មែរ មិន បិត នៅ ត្រឹមតែ ធ្វើ អាទិទេព ឲ ក្លាយ ជា មនុស្ស ភាពខ្ពង់ខ្ពស់ បំផុត ឲ មក ជា ភាព ធម្មតា ភាព អច្ឆរយ ឲ មក ជា ភាព ពិត ប៉ុណ្ណោះទេ គឺ បង្កបង្កើតដែរ ជា មធ្យបាយ សំរាប់ ធ្វើ សកកម្មភាព។ ប្រសិទ្ធិភាព មិនមែន ជា ការសំដែង របស់ បរមត្ថវិជ្ជា នោះទេ តែ ជា ការណ៏និយម ផ្អែក លើ «ចំណេះចេះដឹង» ពិតប្រាកដ និង ការប្រុងប្រយ័ត្ន «ក្នុង ការរស់នៅ និង ការមានប្រយោជន៏»។

ហេតុទាំង នេះ ឯង ដែល ខ្មែរ យក មក ធ្វើ ប្រធានបទ សំខាន់ៗ នៅ ក្នុង «ច្បាប់ខ្មែរ» កំណាព្យ ជា ឧបទេស ជា សង្ខេបនៃ ប្រជាសីលធម៌ខ្មែរ។ នៅក្នុង ភាសា ប្រកប ដោយមនោគតិ សំរាប់ គ្រប់ ស្រទាប់ សង្គមៈ បុរស ស្ត្រី ក្មេង ពិក្ខុ គ្រហស្ថ មន្ត្រី ប្រជាពលរដ្ឋ មហាជន ឲ យល់ ដឹង

អំពី វិធី ធ្វើ ឲ មាន ជោគជ័យ ក្នុង ការរស់នៅ និង ការស្វែងរកសុភមង្គល។

តែ វិធាន ក្នុងលក្ខណ: ជា ច្បាប់ បទដ្ឋាន  គ្មាន ប្រសិទ្ធិភាព ព្រោះ ខ្លួន ឯង កើត ឡើង ពី ច្បាប់ យថាវត្ថុ នៃ ធម្មជាតិ ដែល រៀបរាប់ ខាងក្រោមនេះ៖

- ធម្មជាតិ          អាច ដូរ បាន

- មនុស្សលោក    អាច បត់បែន បាន

- ជា សង្គម          អាត្មានិយម

- ជា ចិត្តសាស្ត្រ      ឥត អាច កែ បាន បែប ផ្ទត់ គំនិតប្រដូចបាន ទៅនឹង កន្ទុយឆ្កែ របស់ ឆ្កែ ដែល គេ មិនអាចពុត ឲ វា ត្រង់វិញ បាន។

អ្វីទាំងអស់ គឺ ផ្អែកលើ បដិវាទកម្ម៖ អ្នក មាន ទ្រព្យ និង អ្នក ក្រខ្សត់ អ្នក មាន រិទ្ធិ និង អ្នក ទន់ខ្សោយ អ្នក ប្រាជ្ញ និង អ្នក ល្ងង់ខ្លៅ អ្នក ចំរើន និង អ្នក ឃ្លាន ដែល នាំ ឲ មាន ការស្អប់គ្នា តែ ម្នាក់ៗ ត្រូវការគ្នា ទៅវិញទៅមកដូចមានចែងនៅក្នុង ច្បាប់ចាស់បុរាណថា៖

អ្នកមានរក្សាខ្សត់   ដូចលំពាត់ព័ទ្ធពីក្រៅ

អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅនូវសំប៉ាន។
អ្នកខ្ពស់រក្សាទាប ដោយសភាពធម៌បុរាណ
អ្នកឆ្អែតរក្សាឃ្លាន នាអ្នករុងរក្សាឆ្នារ។.......

មានទូក ហើយ មាន ថ្នោល មានបង្គោលមានយុថ្កា
ទាំងព្ជួរ ទាំង ច្រវា ក្រជីង ចាប់ ដោយ នូវគ្រប់។
ប្រយ័ត្នក្រែងព្យុះខ្យល់ បក់បោកដល់ នេងទល់ទប់
ប្រយ័ត្នប្រយោជន៍គ្រប់ ទើបហៅជាក់ជាជីវិត។......

វិធាន សីលធម៌ បែបនេះ គឺ ក្នុង បំណង ដោះស្រាយ ទំនាស់ ជា អនន្ត រវាង អាត្មា នឹង អ្នកដទៃ មាន នៅក្នុង វណ្ណៈសង្គម។ ប៉ុន្តែ អ្នកដទៃ ត្រូវ ទុក វា ដូច ជា របស់ ផ្ទាល់ សំរាប់ តែ ខ្លួនឯង គ្រាន់ ជា ការពិបាកយល់ នូវ បរមត្ថវិជ្ជា ពី ព្រោះ អ្នកដទៃ តែងតែ នៅ ក្រោម អាត្មា ក្នុង ភាព ជា ស្រមោល ចាំងចេញ ឬ មធ្យោបាយ ធម្មតា នៃ សមិទ្ធិកម្ម និង ការការពារដល់ខ្លួន។

ព្រោះថា គេ ធ្វើ អំណោយ មិនមែន សំរាប់ តែ អោយ នោះ ទេ។ ភាពបរិសុទ្ធ និង ការមិនគិត ដល់ ប្រយោជន៍ ក្នុង ប

ថ្ជួយ គឺ ជា បរិកប្បសុទ្ធសាត ។ សេចក្តី មេត្តា ករុណា ដូច ជា អ្វីៗ ឯទៀត ដែរ ជា ការស្វែង រកផល៖ ដូចយ៉ាង គេ ចិញ្ចឹមឆ្កែ ព្រោះវា ជា សត្វ ចេះចាំផ្ទះ។ ហើយ ការសុំទាន ជា មធ្យោបាយ ប្រាកដ ដើម្បី រក ការឧបត្ថម្ភ ពី អ្នកដទៃសំរាប់ ជីវិត ក្នុង ជាតិនេះ ហើយ ជៀសវាង កុំ អោយ មាន សេចក្តី ត្រូវការ ចាំបាច់ នូវ ទុគ៌តភាព ហើយ ជា ពិសេស ការប្រកប ការងារ យ៉ាង ពិបាក នៅក្នុង ជាតិក្រោយ។

ជីវិត ការរស់នៅ គឺ គ្មាន មាន សោះ នូវ ការឧបត្ថម្ភ តែ ពោរពេញ ទៅ ដោយ ការខ្វះខាត ហើយ នៅ គ្រប់ ទីកន្លែង មាន កើតឡើង នូវ ការតស៊ូ ស្វែងរកប្រយោជន៍។ មនុស្ស ម្នាក់ៗ ជា ជនអាត្មានិយម ជា ដំបូង ដល់ អាត្មាឯង តែម្តង។ មាន តែ ការវាយតម្លៃ លើ ការប្រាកដនិយម និង ការ ប្រុងប្រយ័ត្ន នៃ ស្ថានភាព និង កាលានុវត្តភាព  នាំ អាច ៙ កែ តម្រូវ តាម មធ្យោបាយ សំរាប់ អនុវត្ត រក គោល បំណង ក្នុង គោលការណ៍ «ការប្រុងប្រយ័ត្ន និងប្រសិទ្ធិភាព»។

តែ ការមិនទុកចិត្ត មាន ជា និច្ច៖ ការមិនទុកចិត្ត ហើយ ការមិនទុកចិត្តទៀត !។ ធម្មជាតិ មិន បាន កើត ឡើង ជា «ខ្សែត្រង់» នោះឡើយ៖ ក្នុងព្រៃ មាន ដើមឈើ ជា

ច្រើន មាន មែកត្រង់ វៀចវេច ច្របូកច្របល ជា មួយគ្នា ក៏ ដូចគ្នានឹង គុណសម្បត្តិ និង គុណវិបត្តិ របស់ មនុស្ស ការធ្វើខុស ការធ្វើត្រូវ របស់ អ្នកដឹកនាំជាតិ នោះដែរ។

ជា ការពិតណាស់ហើយ ការជួយគ្នា ទៅវិញទៅមក រវាង អ្នកធំ អ្នកតូច ជា ការសមស្របនឹង ច្បាប់ធម្មជាតិ។ តែ ត្រូវប្រយ័ត្ន៖ «ប្រយ័ត្ន អ្នកខ្សត់ គិត តែរស់ នឹងជំនួយ !៖ វ ក៏ អាច ធ្វើ ឲ ដើមឈើ ធំមួយដើម ដែល វា ទុក ជា ទម្រ របស់ វា ស្លាប់បាន»

ត្រូវប្រយ័ត្ន អ្នក មាន ទ្រព្យច្រើន ដែល មាន សទ្ធាជ្រះថ្លា៖ សេចក្តី ទុកចិត្ត ទាំង ងងឹតងងល់ លើ អ្នក ឧបត្ថម្ភ ដល់ អ្នកខ្សត់ ស្រេចឃ្លាន អំណោយ ព្រោះ វា នាំ ឲ អ្នក ឃ្លាន អាច មាន ទុក្ខ ទៅវិញ។

« គួរឲ អាសូរ ដល់សត្វ ជ្រូក បសុបក្សី គោ ក្របី ដំរី ដែល ជឿ ថា ម្ចាស់ ខ្លួន ខំ ចិញ្ចឹម ថែរ ក្សាខ្លួន តែ មិន ដឹង សោះ អំពី គោលបំណង ពិត គឺ យក ខ្លួន ទៅ លក់ដូរ ឬ សំរាប់ បរិភោគ តែប៉ុណ្ណោះ។ (ច្បាប់មហាជន)។

« កំហុស របស់ សត្វ គីង្គក់ និង កង្កែប គឺ ថា មាន ទំនុក ទុកចិត្ត ទាំងស្រុង ទៅ លើ ទឹកភ្លៀង ពេល ណា មាន ផ្លា

ក់ៗម្តងៗ នាំគ្នា ច្រៀង សប្បាយរីករាយ ដោយ មិនបាន គិត ថា ភ្លៀង គឺ ជា ទុយ សំរាប់ ខ្លួន នាំគ្នា ចេញ ពី ជម្រក ដែល ជា ឳកាស ឲ មនុស្ស ចាប់ យ៉ាង ងាយស្រួល យក ទៅ បរិភោគ »

ព្រោះថា ធម្មជាតិ គ្មាន ការទៀងទាត់ ដែលគេ ទុកថា មានពុត ដូចជា គុណភាព មជ្ឈន្តិកៈ របស់ មនុស្សលោក និង សង្គម ដែរ មាន បរិយាយ ក្នុង ច្បាប់ បុរាណ ថាៈ «ផ្លូវ បត់បែន កុំបោះបង់ចោល»។ ដែល ទុក ជា អនុសាសន៍ ព្រោះ អាច ឲ មាន លំនំ តាម បាន ល្អ នឹងច្បាប់ បទដ្ឋាន និង ច្បាប់ យថាវត្ថុ នៃ មនុស្សលោក នេះឯង។

ក្នុង រឿង និទានខ្មែរ សាវ័ក ទី១ ដែល ឲ តម្រាប់ នៃ ការ អនុវត្ត នូវ ច្បាប់ កិរិយា នេះ គឺ «សុភាទន្សាយ» ដែល ខ្មែរ ទុក ជា វិរបុរស មួយ ព្រោះ ហ៊ាន ប្រើ ល្បិត ឬ កុហក ដើម្បី យក រួច ខ្លួន ពី បញ្ហា ដែល ខ្លួន បាន ជួប ប្រទះ ឬ ជួយ អ្នកដទៃ ជា ពិសេស សុជន ឲ រួច ខ្លួន ពី អំពើ ជិះជាន់ ពី សំណាក់ ជនទុច្ចរិត មាន អំណាច។

ពិតមែនហើយ ថា ការណ៍ នេះ វា មិនមែន ដូច ជា សីល ធម៌ របស់ ទស្សនវិទូ កង់ (Kant) ក៏ ដោយ តែ ចំពោះ ខ្មែរ

ជា ការប្រតិបត្តិ នូវ សីលធម៌ ឲ្យ ស្រប តាម ស្ថានភាព ពិត ដែល មាន កើតឡើងៈ

- ការវាយតម្លៃ ពិត និង គិតពីប្រយោជន៍;

- ការប្រុងប្រយ័ត្ន និង ការប្រមាណ ឲ្យត្រូវ;

- សកម្មភាព ត្រូវនឹង កាលៈទេសៈ និង មាន ប្រយោជន៍។

គំនិត ទាំង នេះ គឺ នៅ ក្នុង គោលបំណង ឲ្យ ងាយស្រួល ដល់ ការប្រតិតបត្តិ ដែល ជា ខ្សែ បន្ទាត់ នៃ សីលធម៌ ប្រាកដនិយម ដែល មាន នៅ ក្នុង ច្បាប់ អប់រំខ្មែរ។

ប៉ុន្តែ ប្រាកដនិយម ដ៏ ស្រស់ៗ ជា ច្រើន នេះ វា មាន លក្ខណៈ ជា អសីលធម៌ ដូច្នេះ សួរ ថា តើ ត្រូវ ធ្វើ ដូចម្តេច អាច ជៀសវាង កុំ ឲ្យ វា ធ្លាក់ ចូល ទៅ ក្នុង តែ ការណ៍និយម សំរាប់ យក មក ប្រើប្រាស់ ? ឬ ប្រើ សំរាប់ តែ រកប្រយោជន៍ ? ចម្លើយ នឹង សំណួរ នេះ គឺ ស្ថិត លើ ការបិនប្រសព ប្រកប ដោយ ទេពកោសល្យ របស់ កវី សីលធម៌និយម ក្នុង ការ ផ្ទៃ ការណ៍និយម ឲ្យ ក្លាយ ជា វាចារវិទ្យា ប្រកប ដោយ គុណធម៌ និង សុភនិច្ឆ័យ។ តែ ជួនកាល កវី ទាំងនោះ គាត់ ទ័លច្រកដែរ ព្រោះ គាត់ មិន ចង់យក បរមត្ថវិជ្ជា មក ធ្វើ ជា ដំណោះស្រាយ ក្នុង បញ្ហា ដែល ចោទ ឡើង សុខ

ចិត្ត ប្រតិស្ឋាន ក្នុង ការពិត នៃ សង្គម ដែល ប្រកប ទៅ ដោយ បដិវាទកម្ម គ្មាន ចម្លើយ។

តែ ជា សំណាង ល្អ មួយ នូវ ការសង្គ្រោះ សីលធម៌ខ្មែរ ពី សភាព ខ្យល់និយម ជា អាស់ក្រាម និង អសីលធម៌ ដែល កវីខ្មែរ គ្មាន ដំណោះស្រាយ គឺ ការបញ្ជោក នូវ តម្លៃ នៃ គតិបណ្ឌិត ប្រជាប្រិយ ដែល មាន នៅ ក្នុង សង្គមខ្មែរ ច្រើន ពាន់ ឆ្នាំ មុន សម័យ អង្គរ មកម្លេះ។

ការបដិសេធ នូវ ឧត្តមគតិ និយម អភិសមាចារ ការស្អប់ ខ្ពើម នូវ សន្ទុះ គ្មាន ការពិសោធ ឬ អាទកំបាំង និង បរមត្ថវិជ្ជា ជា មួយ គ្នា នឹង ការចូលចិត្ត នូវ ភាពពិត បញ្ជាក់ បង្ហាញ មួយ ចំណែក នូវ លក្ខណៈ ការរីករាយ ការ ចំអក ឡកឡើយ និង ការកំប្លែង ស្លូត ខ្មែរ។ មាន ជា ភស្តុ តាង នៅ ក្នុង អក្សរសិល្ប៍ខ្មែរ ដូច ជា អវត្តមាន នូវ សោក នាដកម្ម (រឿងកំសត់) និង សុខនាដកម្ម (រឿងកំប្លែង) ឬ សោកនាដកម្ម-សុខនាដកម្ម (រឿង កំសត់ លាយ កំប្លែង) ច្រើន នោះដែរ។ សួរ ថា មក ពី ហេតុអ្វី ?

ដូច ជា អច្ឆរិយៈ ឬ បរមត្ថវិជ្ជា, ទុក្ខសោក ចំពោះ ខ្មែរ ជា អតិរេកភាព ហេតុនេះឯង បាន ជា អក្សរសិល្ប៍ខ្មែរ បដិសេធ នូវ អច្ឆរិយៈ អាទកំបាំង, សោកនាដកម្ម មែន

ទែន និង អតិរេកភាព ដទៃទៀត មាន នៅ ក្នុង អារម្មណ៍ នៃ ការត្រិះរិះ  និង អំពើ នៃ មនុស្សលោក។ នៅ ក្នុង រឿង កំសត់ នៃ ជនជាតិ ក្រិច (grecque) តួឯង ជា វិរបុរស តែងតែ ស្លាប់ ជា និច្ច បន្ទាប់ ពី បាន ធ្វើ ការតស៊ូ ក្រៃលែង នាំ ឲ អ្នកអាន មាន ការតានតឹង ក្នុងចិត្ត ស្ទើរទ្រាំពុំបាន។

ឯ ចំណែក ក្នុង រឿងខ្មែរ វិញ ដែល មាន ជម្មជាតិ រីករាយ សុទ្ធិដ្ឋិនិយម ចំអកឡុកឡើយ សើចក្តី សប្បាយ ប្រាកដនិយម តែ មាន មនោសញ្ចេតនា ស្អប់ខ្ពើម នូវ អំពើឃាតកម្ម។ ហេតុនេះឯង បាន ជា ក្នុង អក្សរសិល្ប៍ នៃ សោកនាដកម្ម ឬ រឿងជីវិតពិត ខ្មែរយើង មិន ងាយ ធ្លាក់ ក្នុង អន្ទាក់ នូវ ការកំសត់នេះឡើយ។ ជម្មជាតិ ដែល បាន រៀបរាប់ ខាង លើ នេះ ជួនកាល នាំ ឲ អ្នកអាន បែរ ជា សើច ដោយ បង្ខំ នូវ ការកំសត់ របស់ តួឯក ទៅវិញ។ នេះ ជា អារម្មណ៍ នៃ មនុស្ស គ្មាន បញ្ហា ឬ ជា មនុស្ស ទាល់ច្រក ក្នុង ជីវិត រស់នៅ ឬ មកពី ភាពកំសត់ នោះ វា មាន ភាព ហួសហេតុ ពេក។

ជា និច្ចកាល អតិរេកកម្ម និង អច្ចន្តភាព  ត្រង ជា តម្លៃ អវិជ្ជមាន នៅ ក្នុង អក្សរសិល្ប៍ខ្មែរ។ គេ សង្កេត ឃើញ ថា

តួអង្គ នៅ ក្នុង រឿងខ្មែរ យំ រហ័យ ណាស់ ជួនកាល រហូត ដល់ សម្លប់ តែ ម្តង ហើយ អ្នកនិព័ន្ធ ពិពណ៌នា ការសូរយំ អណ្តឹតអណ្តន់ នេះ ជួន កាល មួយ ទំព័រ ទាំងស្រុង។ តែទឹកភ្នែក នេះ ជួនកាល មិន មែន ជា ការយំ ពី ទុក្ខ នោះឡើយ តែ ជា សញ្ញា នៃ សេចក្តីត្រេកអរ ក្នុង សុភមង្គល ណាមួយ។ ដូច្នេះ តួអង្គ ក្នុងរឿងខ្មែរ គាត់ យំ ព្រោះ មាន ទុក្ខ ផង និង យំ ព្រោះ ជួបប្រទេះនឹង សេចក្តីសុខ ផង ដែរ។ ទឹកភ្នែក សំរាប់ ខ្មែរ មាន តួនាទី ជា សរិរសាស្ត្រ  ច្រើន ជាង ជា សោភ័ណ ។ សួរ ថា តើ សេចក្តីរីករាយ ដូច គ្នា នឹង ការ ឈឺចាប់ គ្មាន កំរិត (seuil) នៃ ចិត្ត-សេរីរៈ  តាម ផ្លូវ នេះ នាំ ឲ កំប្លែង អាច ទៅ ជា កំសត់ ឬ កំសត់ អាច ទៅ ជា កំប្លែង វិញដែរ ? ចំណុច នេះ អាច ពន្យល់ បាន អំពី ទម្រេត របស់ខ្មែរ ទៅ ក្នុង សោកនាដកម្ម-សុខនាដកម្ម (យំ ផង សើច ផង) ដូច មាន នៅ ក្នុង៖

- ភាពអណ្តែតអណ្តូង នាំ មក នូវ ទឹកភ្នែក តែ មាន សំណើច ;

- ភាពរំជួលចិត្ត តែ គ្មាន មរណភាព និង គ្មាន «ទុក្ខ ប្រចាំជីវិត» ;

- ភាពអន្លង់អន្លោច តែ គ្មាន ភាពសង្រេងសង្រៃ ហើយ បញ្ឆាន់ ជា ថ្មី ដែល សម្លាប់ បន្តិច ម្តងៗ ឲ ក្សៀយចិត្ត !

ដោយ គិត តែ ពី សម្រក់ទឹកភ្នែក ដើម្បី រក សមតា នូវ ចិត្ត-សេរីរះ គេ លែង ដឹង ថា តើ សម្រែក យំ នោះ វា ពិត ប្រាកដ មែន ដែរ ឬទេ។ តែ នៅ ក្នុង រឿង ទុំទាវ មាន ភាព ប្រក្រតិ ព្រោះ ជា រឿង សោកនាដកម្ម គួរ ឲ រន្ធត់ ពិត ប្រាកដ ដែល ពិបាកនឹង យល់ស្រប បាន ចំពោះ ខ្មែរ។ ទុំ និង ទាវ មិន ប្រពៃ យក សេចក្តី ស្នេហាគ្នា តាម ចិត្ត ស្រឡាញ់  ហើយ យក សេចក្តីស្លាប់ ដាច់ខាត ជា ចម្លើយ ចំពោះ មុខ បញ្ហា ដែល ខ្លួន បាន ជួបប្រទះ។ ភាពអច្ឆរិយ ហួសហេតុ នេះ ហើយ ដែល ខ្មែរ មិន សូវ អោយ តម្លៃ ដល់ សេចក្តីស្នេហា រវាង នេន ទុំ និង នាង ទាវ ថា ជា សេចក្តី ស្នេហា មិន គួរ យក ជា គំរូ ដែល នាំ អោយ មាន ការអត់ អោនខ្លះ ដល់ អ្នក ផ្ញើឃាត ដល់ គូរ ស្នេហ៍។ ហេតុនេះឯង បាន ជា យុវជនខ្មែរ មិន ដែល ទុក ទុំ និង ទាវ ជា វរបុរស និង វរនារី ហ៊ាន បូជា ជីវិត សំរាប់ សេចក្តីស្នហា ពិមល នេះ ឡើយ។ មិន តែ ប៉ុណ្ណោះ ជួនកាល រហូតដល់ ចោទ ទុំ ថា ជា មនុស្ស គ្មាន ការទទួលខុសត្រូវ ព្រោះ យក សេចក្តីប្រចាន់ ហួសហេតុ ដាក់ ក្នុងចិត្ត ផឹក សុរា ស្រវឹង នាំ ឲ ខ្លួន ភ្លេច

អស់ នូវ បញ្ញា ស្តេច ជា លាយលាក់ អក្សរ ដែល ជា អាជ្ញា សំរាប់ រំដោះ នាង ទាវ ជា ភរិយា ពី អំណាច មាតា របស់ នាង។ ហេតុនេះឯង បាន ជា មាន មតិ ខ្លះ ទុក មរណភាព ទុំ និង ទាវ ជា មរណភាព ឥតប្រយោជន៍ មិន គួរ យក គម្រាប តាម។

រឿង នេះ ក៏ ដូច គ្នា នឹង នាង ស៊ីតា ខឹង នឹង ស្វាមី (ព្រះរាម) បញ្ចប់ នូវ ការរក សព្វ ការសម្របសម្រួល ជា ដាច់ខាត ជា មួយ ស្វាមី ព្រោះ តែ ព្រះអង្គ ចោទ ប្រកាន់ ដល់ រូប នាង ថា ធ្លាប់ សេពមេថុធម្ម ជា មួយ រៀប ជា ស្តេច យក្ស។ ការបដិសេធ នេះ ដែល ខ្មែរ ភាគច្រើន មិន ទុក នាង ស៊ីតា ជា វីរនារី ក្នុង រឿង រាមកេរ៍ខ្មែរ រហូត ជួនកាល ទុក នាង ស៊ីតា ជា ជនអាត្មានិយម ទៀតផង ព្រោះ នាង ស៊ីតា ធ្លាប់ បាន ស្បថស្បែ ជា មួយ ស្វាមី ថា ស្លាប់រស់ ជា មួយ គ្នា...។

ការសាកល្បងពិចារណា អំពី ទិដ្ឋភាព នៃ អក្សរសិល្ប៍ខ្មែរ របស់ លោក កេង វាន់សាក់ បង្ហាញ ថា អ្នកប្រាជ្ញខ្មែរ ផ្នែក គំនិត ទាំង វិស័យ អក្សរសិល្ប៍ ពុទ្ធសាសនា ក្តី វិស័យ អក្សរសិល្ប៍ សាមញ្ញ ក្តី លោក មាន មនោគតិ (imagination) ខ្ពង់ខ្ពស់ ណាស់ ក្នុង ការ និព័ន្ធ អត្ថបទ ប្រកប ទៅ ដោយ

គំនិត ប្រាកដនិយម ផង និង អោយ មាន សោភណភាព ផង សំរាប់ ទាក់ទាញ អារម្មណ៏ អ្នកអាន អោយ ចង់ អាន។ សិល្ប: នៃ និព័ន្ធ រចនា (l’art de l’écriture) របស់ អ្នកប្រាជ្ញ ខ្មែរ មាន ពិត ប្រាកដ ទាំង តាម ការប្រើ ពាក្យប្រៀប ក្តី ទាំង ពាំនោល ក្តី បង្ហាញ ដែរ ថា អ្នកនិព័ន្ធខ្មែរ មាន សុមេធា (art de maitriser les passions) ក្នុង និព័ន្ធ រចនា របស់ ខ្លួន ហើយ ថែម ទាំង ចេះ ឆ្នៃ ប្រឌិត នូវ អក្សរសិល្ប៍ បរទេស ដែល ហូរចូល មក ក្នុង ស្រុកខ្មែរ អោយ មាន លក្ខណ: ជា ខ្មែរ ដើម្បី អោយ ខ្មែរ គ្រប់ មជ្ឈដ្ឋាន អាច ស្រួល យល់ អំពី ជម្រៅ គំនិត នៃ អត្ថបទ។ អ្នកនិព័ន្ធខ្មែរ តែងតែ ធ្វើ សមារម្ភ (effort, ardeur au travail) ដើម្បី ចង ជា ចំណង អារម្មណ៏ ក្នុង ការសរសេរ របស់ ខ្លួន នឹង អារម្មណ៏ នៃ មនោគតិ របស់ អ្នកអាន នៅ ក្នុង ទំហំ សេរីភាព របស់ អ្នកអាន ព្រោះ អ្នកអាន នេះ ឯង ជា អ្នក ទទួល ខុសត្រូវ ក្នុង វិស័យ អារម្មណ៏ ផ្ទាល់ខ្លួន លើ គំនិត នៃ អ្នកនិព័ន្ធ។

បញ្ញាវន្តខ្មែរ ទាំង សម័យ អង្គរ សម័យ កណ្តាល សុទ្ធ ជា បញ្ញាវន្ត ពិត ប្រាកដ មាន ឧត្តមគតិ មាន ប្រាជ្ញា មាន គំនិត ជាតិនិយម គំនិត ស្នេហាជាតិ ទោះបី ពួក គាត់ រស់ នៅ ក្នុង បរិស្ថាន អរិភូត (hostile) នឹង បញ្ញា ការផ្តួតផ្តើ

ម នៃ ការ និព័ន្ធ រចនា របស់ ពួក គាត់ ព្រោះ សង្គមខ្មែរ ជា សង្គម អភិរក្ស តែងតែ ទុក គំនិត ថ្មី ជា គំនិត ប្រឆាំងនឹង ប្រពៃណី របស់ សង្គម។ នៅ ក្នុង បរិស្ថាន អរិភូត នេះ នាំ អោយ បញ្ញាវន្តខ្មែរ ភាគច្រើន និព័ន្ធ អត្ថបទ ជា អ្នកនិព័ន្ធ អនាមិក ដើម្បី រក្សា សុវត្ថិភាព របស់ ខ្លួន។ បញ្ញាវន្ត ទាំង នោះ សុទ្ធ ជា អ្នកវឌ្ឍននិយម ធ្វើ ការតស៊ូ មតិ ក្នុង គោលបំណង ធ្វើ កំណែទំរង់ វិធី នៃ ចិត្តនាការ ចាស់ ដែល ជា កត្តា អវិជ្ជមាន ដល់ ការការរីកចំរើន នៃ សង្គម។




# សេចក្តីសន្និដ្ឋាន

ខ្មែរយើង ដឹង ថា ប្រជាជាតិ ខ្លួន មាន មរតក វប្បធម៌ ខ្ពង់ខ្ពស់ មាន មូលដ្ឋាន បញ្ញាជាតិ ពិត ប្រាកដ ជា ប្រទេស មាន អារ្យធម៌ រស់រវើក ដូច មាន កេតនភ័ណ្ឌ ជា ច្រើន ជា ភស្តុតាង នៃ អត្តភាព វត្ថុពិត ទាំងឡាយ នោះ។ តែ មោទនភាពខ្មែរ មិន ស្ថិត នៅ លើ តែ ពាក្យ ថា ស្រឡាញ់ជាតិ នោះឡើយ គឺ ថា ត្រូវ យល់ ដឹង ច្បាស់ អំពី តម្លៃ នៃ ប្រជាជាតិ ខ្លួន។ ដើម្បី មាន ភ័ព្វ អាច យល់ ដឹង នូវ តម្លៃជាតិ ខ្មែរយើង ត្រូវ មាន គំនិត ថ្មី ដើម្បី ធ្វើ ការ ពិចារណា អំពី គំនិត ចាស់ ខ្លះ ដែល ជា គំនិត វា បំពុល សង្គមខ្មែរ ពី អតីតកាល ហើយ វា គ្មាន ចំណង អ្វី បន្តិច សោះ សំរាប់ ការរស់នៅ នា បច្ចុប្បន្នកាល នេះ។ គេ ដឹង ថា អតីតកាល និង បច្ចុប្បន្នកាល ជា ពេលវេលា តែ មួយ។ ដូច្នេះ គឺ អាច ទុក ជា ការធ្វេប្រហែស មួយ ដែល ចង់ យល់ ដឹង អំពី ព្រឹត្តិការណ៍ កើត មាន ឡើង ក្នុង អតីតកាល ដោយ មិន យក វា មក ផ្ទុះ មើល អ្វី ដែល មាន កើត ឡើង នៅ ក្នុង បច្ចុប្បន្នកាល។ តែ ក៏ ជា កំហុស មួយ ដែរ ដោយ យក ព្រឹត្តិការណ៍ ក្នុង កាលៈទេសៈ នៃ បច្ចុប្បន្នកាល មួយ ទៅ ធ្វើ ការបកស្រាយ លើ ព្រឹត្តិការណ៍ ដែល មាន កើត

ឡើង នៅ ក្នុង អតីតកាល។ តែ ទំនាក់ទំនង របស់ វា គឺ ដូច ជា មាន ខ្សែទឹក ពី អតីតកាល ទៅ បច្ចុប្បន្នកាល ហើយ អតីតកាល ពន្យល់ ដល់ បច្ចុប្បន្នកាល ក្នុង ភាសា សាមញ្ញ ប្រកបដោយ បញ្ញាភា ដើម្បី រស់ រួមគ្នា នៅ ក្នុង ជីវិត តែមួយ។ ដោយអកុសល ខ្សែទឹក នៃ បញ្ញាខ្មែរ ត្រូវ បាន បដិវត្តន៍ របស់ ពួក ខ្មែរក្រហម កាត់ផ្តាច់ ហើយ រំលាយ អោយ សាបសូន្យ នូវ អ្វី ជា សញ្ញា នៃ បញ្ញាខ្មែរ។ ហើយ បច្ចុប្បន្នកាល ប្រជាពលរដ្ឋខ្មែរ ដឹកនាំ ដោយ របប ផ្តាច់ការ ហើយ ជា នគរ រណប យួន ដែល កំពុង ផ្តិតពុម្ព ថ្មី នៃ បញ្ញាខ្មែរ ទៅ តាម ប្រយោជន៍ របស់ ពួក អ្នកដឹកនាំ ដែល គេ ចង់បាន។ ការត្រួតត្រា នៃ បញ្ញា ឬ បញ្ញាវន្ត ជា អាទិភាព របស់ របប នយោបាយ សព្វថ្ងៃ។ ដើម្បី ងាយ ស្រួល ត្រួតត្រា មជ្ឈដ្ឋាន នៃ អ្នកចេះដឹង គេ ធ្វើ អោយ មជ្ឈដ្ឋាន នោះ រស់នៅ ក្នុង ភាពនៅក្នុងចំណុះ នៃ អំណាច ដឹកនាំ ទាំង នៅ ក្នុង វិស័យ ហិរញ្ញវត្ថុ និង ឋានន្តរស័ក្តិ។ ពួក អ្នកដឹកនាំ គេ នាំ គ្នា ពាក់ងារ ជា បណ្ឌិត ដើម្បី ស្ថិត ជា ប្រពន្ធិក លើ មជ្ឈដ្ឋាន អ្នកចេះដឹង ហើយ ជា ការបញ្ជាក់ បង្ហាញ ពី វិសិដ្ឋភាព នៃ បញ្ញា របស់ គេ សោតទៀត។ សព្វសញ្ញា (mot d’ordre) របស់ ពួក អ្នកដឹកនាំ សព្វថ្ងៃ គឺ « អំណាច ជា បញ្ញា » គឺ ថា មាន អំណាច គឺ មាន បញ្ញា។

អ្នកចេះដឹង ណា ម្នាក់ ហ៊ាន មាន គំនិត ក្រៅ ប្រព័ន្ធ នោះ ឬ មិននៅ ក្រោម ចំណុះអំណាច គឺ អាចនឹង មាន គ្រោះថ្នាក់ ដល់ ជីវិត ជា ពុំខាន។ បញ្ញាវន្ត សព្វថ្ងៃ ដើម្បី រស់ ឬ មួយ បើ អ្នក នោះ ស្រឡាញ់ បុណ្យស័ក្តិ និង លោភ លុយ កាក់ ត្រូវ សុទ្ធចិត្ត រស់ ក្នុង ប្រតិបាទគ៏ (soumission) នៃ អំណាចដឹកនាំ ឬ មួយ បើ អ្នក នោះ មាន ស្មារតី ពិត ជា បញ្ញាវន្ត ត្រូវ រស់ នៅ ក្នុង ជីវភាព ក្រលំបាក ឬ ទទួល ការ គំរាម ដល់ សុវត្ថិភាព ជា អចិន្ត្រៃយ៍ ពី សំណាក់ អំណាច ដឹកនាំ។

សង្គមខ្មែរ សព្វថ្ងៃ គ្មាន ការរីកចំរើន ក្នុង ផ្នែក សតិបញ្ញា និង គតិលោក គតិធម៌ នាំ អោយ អ្នកចេះដឹង រស់នៅ ក្នុង អារម្មណ៏ ស្រណោក និង ខកចិត្ត ព្រោះ ពន្លឺ ចំណេះ ចេះដឹង របស់ ខ្លួន  ពុំ អាច បំភ្លឺ សង្គម  គ្រលង់ (société cruelle) ស្ថិត នៅ ក្នុង ភាពងងឹត ដែល ជា កន្លែង រស់នៅ របស់ ពួក តិរច្ឆាន។ ពួក អ្នកដឹងនាំ សព្វថ្ងៃ គេ ធ្វើ គ្រប់ បែបយ៉ាង មិន អោយ បញ្ញាវន្ត មាន ឧត្តមគតិជាតិ ព្រោះ វា ជា សត្រូវ នឹង នឹង អំណាច របស់ ពួក គេ។ សំដី តែ មួយ

គាត់ ដែល គេ លើក យក មក ការពារ គឺ ពាក្យ សន្តិភាព តែ ជា ពាក្យ ប្រើ សំរាប់ តែ ការពារ បុព្វសិទ្ធិ របស់ ពួក គេ

តែ ប៉ុណ្ណោះ។ សង្គម គ្មាន ពន្លឺ បញ្ញាភា សំរាប់ បំភ្លឺ ទោះបី មាន សន្តិភាព គឺ ជា សង្គម ខ្វះ ទស្សនវិស័យ នៃ អានាគត រស់ សំរាប់ រស់ តែ មួយ សំណើ (un moment) ដែល ខ្មែរ យើង និយាយ ថា រស់ មួយ គ្រែ។ គ្រោះថ្នាក់ សង្គម បែប នេះ គឺ គ្មាន អ្វី សំរាប់ ការពារ ខ្លួន នូវ ការហូរចូល នៃ ជនជាតិ យួន រាប់លាន នាក់ ដែល ជា អន្តោប្រវេសន៍ រៀបចំ ច្បាស់លាស់ ដោយ វៀតណាម សំរាប់ យក ដី ខ្មែរ ទុក ជា ជីវទីកដី (espace vital) សំរាប់ ចិញ្ចឹម ប្រជាជនយួន។ សន្តិភាព ដែល ពួក អ្នកដឹកនាំខ្មែរ គេ ខំ ការពារ នោះ ជា វិធានការ នៃ ការតាមជូន ដំណើរ នយោបាយ អន្តោប្រវេសន៍ របស់ វៀតណាម នៅ ក្នុង ស្មារតី នៃ កតវេទិតា (remercie sans fin) តបស្នងគុណ ដល់ អ្នកមានគុណ គឺ កងទ័ពយួន ដែល មាន ថ្ងៃទី៧ មករា ជា ថ្ងៃ បុណ្យរំឭកខួប។ អវត្តមាន នៃ អភិចលនា នៃ វិវាទកម្ម[27] របស់ ខ្មែរ ជា ពិសេស យុវជន និង បញ្ញាវន្ត នៅ ចំពោះមុខ បុណ្យរំឭកខួប នោះ បញ្ជាក់ អោយ ឃើញ ថា អ្នកចេះដឹងខ្មែរ នាំ គ្នា រស់ សំរាប់ តែ ជីវិតអាត្មា ព្រោះ ខ្លួន នាំ គ្នា យល់ឃើញ នៅ

[27] អភិចលនា នៃ វិវាទកម្ម; effervescence de contestation។

ក្នុង ស្មារតី នៃ ចាគប័ត្រ ថា ខ្លួន គ្មាន  សមត្ថភាព និង មធ្យោបាយ  សំរាប់  ទប់ទល់នឹង  អន្តរាយជាតិ។  បញ្ញាវន្ត ខ្មែរ  សព្វថ្ងៃ  គ្មាន  កម្លាំង  រៀបចំ  ជា  កម្លាំងបញ្ញាជាតិ ទោះបី ពួកខ្លួន រស់ នៅ ជា ក្រុមសាកលវិទ្យាចារ្យ (corps des universitaires) មាន ទំនាក់ទំនង ដោយចំពោះ ជា មួយ យុវជន។ សួរ ថា តើ ការចេះដឹង នៅ ក្នុង សង្គមខ្មែរ សព្វថ្ងៃ មាន ប្រយោជន៍ អ្វី ដល់ ប្រជាពលរដ្ឋខ្មែរ ?

**ថ្ងៃទី ២៣ កុម្ភៈ ឆ្នាំ ២០១៧**